ទុក្ខលំបាកឡើយទេ អស់មានទុក្ខភ័យអ្វីទៀតហើយ តែព្រលឹងនេះ កាលបើចេញអំពីព្រហ្មទៅហើយ ទៅព្រហ្មវិញបានឡើយទេ ទៅកើតជាមនុស្ស ឬ អ្វី ទុក្ខលំបាក ហើយបេះតែកើតកើតទៅទៀត បានទុក្ខលំបាក មិនមែនសុទ្ធតែកើតជាមនុស្សជាប់តទៅទេ ជួនកាលកើតជាសត្វតិរច្ឆាន ជាសត្វនរកទទួលទុក្ខ ឬ ក៏ត្រឡប់មកកើតជាមនុស្សវិញ ល្អខ្លះ អាក្រក់ខ្លះ វិលវល់ទៅមកយ៉ាងនេះ ។ នេះហើយជាដើមកំណើត ដែលនាំឲ្យកើតពាក្យថា «សង្សារ» ពាក្យថា សង្សារនេះ កើតមានមុនពុទ្ធសាសនាហើយ គឺកើតឡើងតាំងតែពីសម័យព្រាហ្មណ៍នេះឯង ។

អាត្មាដែលត្រូវវិលវល់កើតស្លាប់ បានទទួលទុក្ខលំបាកយ៉ាងនេះ មិនមានអំណាចទេពតាឃាត់ហាម មិនឲ្យកើតទៅទៀតបានទេ ព្រោះតែមាន «កម្ម» ដែលមនុស្សធ្វើ ។ ពាក្យកម្មនេះក៏កើតឡើង ពាក្យថា «កម្ម» នេះ ក៏មានមកហើយ

គន្ធសាសនាព្រាហ្មណ៍ មុនកើតពុទ្ធសាសនាឡើង ។ សេចក្តីថា លុះត្រាតែធ្វើសេចក្តីល្អឲ្យលើសលប់ ឲ្យច្រើនកប់លិចបាត់ការខុស ការអាក្រក់អស់ហើយ ទើបព្រលឹងត្រឡប់ចូលទៅកាន់ព្រហ្មវិញបាន នេះផុតទុក្ខអស់ហើយ មានតែសុខប្រសើរផុត ៗ សេចក្តីនេះ ប្រៀបដូចទឹកមហាសមុទ្រទៀត ទឹកទាំងអស់មិនថាទឹកអ្វីទេ សុទ្ធតែមកពីមហាសមុទ្រទាំងអស់ ទីបំផុតវិលចូលទៅកាន់នពមហាសមុទ្រវិញ តែមុននឹងចូលទៅនពមហាសមុទ្រ ត្រូវវិលវល់អស់កាលយូរណាស់ ចូលទៅទៅតាមជ្រោះជ្រលងភ្នំស្ទឹងបឹងទន្លេ មិនងាយនឹងចូលទៅសមុទ្រវិញបានភ្លាមទេ ព្រោះស្ទឹងបឹងទន្លេ អាចនឹងកួចឲ្យវិលទៅវិញទៀត ឬជ្រាបចូលទៅក្នុងផែនដី គេដឹក គេប្រើប្រាស់ លាងគ្រឿងស្មោកគ្រោក ទៅជាទឹកស្អុយអាក្រក់ ឬទៅជាទឹកល្អស្អាត ឬពុំនោះទៅជាទឹកអប់ក្រអូប ទឹកមន្ត ឬទឹកថ្នាំអ្វីមួយ បើអាចចូលទៅកាន់នពមហាសមុទ្រវិញបានក៏

ត្រូវអស់កាលវេលាយូរអង្វែងដែរ តែទោះដូចម្ដេចក្ដី ទីបំផុត ទឹកនោះ ៗ ត្រូវតែហូរទៅកាន់មហាសមុទ្រវិញ ។

ដោយការជឿយ៉ាងនេះ សេចក្ដីសង្ឃឹមរបស់មនុស្ស ទើបកើតឡើងថែមទៀត ជាសេចក្ដីសង្ឃឹមដ៏មាំក្រៃលែង គឺសង្ឃឹមថា នឹងគេចឲ្យរួចការវិលកើតស្លាប់ ដែលជាសេចក្ដីទុក្ខនៃសត្វលោក ដោយការប្រតិបត្តិឲ្យព្រលឹងចូលទៅរកព្រហ្មដែលមិនមានការកើតទៅទៀត ។ ការគិតឃើញទាំងនេះ បែកខ្នែងកើតទៅជាលទ្ធិសាសនា កើតមានសាស្ត្រាចារ្យទាំងឡាយច្រើននាក់ ស្វះស្វែងព្យាយាមបំពេញខ្លួនឲ្យជួបវិធីដែលនាំព្រលឹងចូលទៅរកព្រហ្ម ឲ្យឆាប់បំផុត ដែលនឹងអាចឆាប់បាន ដូច្នេះ សេចក្ដីត្រូវការមនុស្ស ក៏ឡើងទៅកាន់ថ្នាក់ខ្ពស់មួយថ្នាក់ទៅទៀត គឺកាលដើមមុនលទ្ធិព្រហ្ម មនុស្សសែន បួងសួង បន់ស្រន់ទេពតា ដើម្បីឲ្យបានលាភសក្ការៈ

ដើម្បីសុខភាព ដើម្បីឲ្យមានកូនប្រុស ដើម្បីឲ្យមានអាយុវែង អនាគតជីវិត គឺ ការស្លាប់ទៅហើយ សូមឲ្យកើតទៀតបានល្អ ជាងជាតិនេះ ឬ ឲ្យកើតក្នុងឋានសួគ៌ តែលទ្ធិអាត្ម័ន ជា ផលរបស់ការមានព្រហ្ម ការគិតរបស់មនុស្សបានជឿនលឿន ទៅទួសទៀត គឺ ត្រូវការសេចក្តីសុខ ដែលមិនត្រូវកើតទៀត ដែលហៅថា "អម្រឹត=មិនស្លាប់" ។

ការផ្លាស់ប្តូរដ៏សំខាន់ដល់កម្រិតទួសនេះ កើតមកពីការ ប្រកាន់ជឿលទ្ធិអាត្ម័ន ដែលជាលទ្ធិ "ខ្លួនឯង" ជំនឿដើមពី អតីតកាល គឺ ក្នុងសម័យអារ្យ័នក្តី សម័យត្រៃវេទក្តី សេចក្តី ល្អ សេចក្តីអាក្រក់ ផលអាក្រក់ ដែលកើតឡើងនោះ មិន មែនកើតឡើងដោយឯកឯងនោះទេ គឺកើតឡើងដោយទេវតា បណ្តាលឲ្យ ទើបកើតឡើងបាន តែលទ្ធិ "អាត្ម័ន-ខ្លួនឯង" មិន ដូច្នោះទេ លទ្ធិអាត្ម័នបានសាងគោលការថ្មីមួយទៀត គឺផល ល្អផលអាក្រក់នោះ ជាអំពើរបស់ខ្លួន ដូច្នេះពាក្យថា "កម្ម"

ជាដើម ក៏ចាប់កំណើតឡើង ដោយអាស្រ័យការគិតទាំងអស់នេះ ជាបច្ច័យធ្វើឲ្យមនុស្សលះទទួលខុសត្រូវដោយខ្លួនឯង ។ លោកស្ត្រូស (Otto Strauss) ជាអ្នកប្រាជ្ញអាល្លឺម៉ង់សរសេរទុកថា លទ្ធិភក្តិនេះ ជាការផ្ដើមគំនិតមនុស្សឲ្យដើរទៅកាន់វិថីត្រូវ គឺទៅកាន់វិថីសម្មាទិដ្ឋិ នៅក្នុងវិថីជីវិតនៃមនុស្សជាតិ ជាការផ្ដើមដ៏សំខាន់មួយដល់ចិត្ត ព្រមទាំងជាការបង្រៀនមនុស្សឲ្យលះបង់ទទួលខុសត្រូវដោយខ្លួនឯង ព្រោះកាលពីដើមឡើយ មនុស្សចង់បានអ្វី ៗ ត្រូវសុំទៅទេពតា តែលទ្ធិភក្តិបង្រៀនថា ត្រូវធ្វើខ្លួនឯង ត្រូវពឹងខ្លួនឯង សូម្បីការចូលទៅកាន់ព្រហ្ម ឬ ចង់ឲ្យព្រលឹងរបស់ខ្លួនចូលទៅកាន់ព្រហ្ម ក៏មិនមែនសម្រេចដោយពិធីបួងសួងបន់ស្រន់បូជាទេ សេចក្ដីពិត តាំងតែពីកើតលទ្ធិព្រហ្ម គឺលទ្ធិភក្តិនេះឡើង រឿងសែន បួងសួង បន់ស្រន់ បូជា សុំអ្វីពីទេពតានៅលើឋានសួគ៌ គេមិនសូវប្រកាន់ថាជាវិធីប្រសើរ គឺត្រូវតែ

ប្រតិបត្តិខានមិនបាននោះទេ សូម្បីតែព្រះព្រហ្មដែលគេប្រកាន់ជឿថា ជាទេពតាខ្ពស់ផុតក៏ដោយ ក៏គេមិនធ្វើពិធីសែនបួងសួងបូជាដែរ គេមានពិធីប្រតិបត្តិប្រសើរមួយ ដែលគេបញ្ញត្តឲ្យកើតឡើង ជាពិធីខ្លួនឯងជួយខ្លួនឯង គឺធ្វើដោយខ្លួនឯងក្នុងខ្លួនឯង ដើម្បីខ្លួនឯង ព្រោះខ្លួនឯងនោះគឺព្រហ្ម ការធ្វើដោយខ្លួនឯងជាអំពើរបស់ព្រហ្ម ការប្រព្រឹត្តិប្រតិបត្តិបែបនេះបានឲ្យកើតលទ្ធិមួយទៀត ហៅថា «ឧបនិស័ទ» ។

៣– ឧបនិស័ទ. ឧបនិស័ទ ជាគម្ពីរថ្មីមួយ កើតឡើងបន្ទាប់ពីសម័យព្រាហ្មណៈ គេហៅឈ្មោះមួយទៀត ថា «វេទាន្ត» ប្រែថា «ខាងចុងវេទ ឬថា កំពូលវេទ» ជាលទ្ធិដែលគេគន់គិតឃើញ ហើយគេបញ្ញត្ត សម្រាប់អធិប្បាយពន្យល់លទ្ធិព្រាហ្មណៈ ដែលមានការផុះផាលចំរើនទៅតាមកាលៈ ទេសៈ ឬ បើនិយាយមួយបែបទៀតគឺ «ជាពាក្យអធិប្បាយពន្យល់គោលលទ្ធិព្រហ្មនិភ័ន្ធ» ។

គម្ពីរឧបនិស័ទ មានបែបបទដូចគម្ពីរវេទដែរ មានគម្ពីរដែលគេទុកជាកណ្ដាល ហើយដែលគេទទួលស្គាល់ជាច្បាប់ពិតប្រាកដនោះទេ ព្រោះមិនមានការសង្គាយនាដូចព្រះត្រៃបិដកក្នុងពុទ្ធសាសនា គឺជាគម្ពីរដែលមានមនុស្សច្រើននាក់សរសេរ ហើយចងជាទ្រឹស្ដីតាមសេចក្ដីយល់ឃើញរបស់ខ្លួនម្នាក់ ៗ បានរួមទៅជាគម្ពីរមួយនេះឡើង ក្នុងសម័យជាន់ក្រោយណាស់ទៅហើយ ។ គម្ពីរឧបនិស័ទនេះ កើតឡើងច្រើនសម័យច្រើនគ្រាណាស់ តាំងពីបុរាណព្រេងនាយ គឺសម័យពីបុរាណ សម័យកណ្ដាល សម័យថ្មី តែគោលធំនោះ គេជឿកាន់គ្រប់សម័យ ព្រោះមានតែបំណងតែមួយ គឺស្វែងរកវិធីដែលនឹងធ្វើឲ្យព្រលឹងរបស់មនុស្ស វិលត្រឡប់ចូលទៅកាន់ព្រហ្មវិញប៉ុណ្ណោះ ។

លោក អុត្តូ ស្ត្រូស (Otto Strauss) ជាអ្នកប្រាជ្ញអល្លឺម៉ង់ ជាអ្នកត្រិះរិះវិជ្ជាឥណ្ឌាដ៏នាញម្នាក់ បានគេគិតគំរិត

អាយុគម្ពីរឧបនិស័ទជាន់ចាស់បំផុតនោះ ត្រឹមវេលាមុនពុទ្ធកាល ប្រមាណជាមួយសតវត្សរ៍គឺ ១០០ ឆ្នាំប៉ុណ្ណោះ ៗ ពុទ្ធសាស-នានិងសាសនាជេនដែលកើតឡើងក្រោយ បានគន់គិតពិចារ-ណាបន្តទៅ តាមស្នាមគំនិតរបស់ឧបនិស័ទ ដែលគេគិតមកហើយដែរ មានគោលបំណងតែមួយ គឺបំបាត់ការវិលវល់កើតស្លាប់ ធ្វើវិញ្ញាណឲ្យរួចស្រឡះ ចាកការជំពាក់ទាំងឡាយពីបំផុតឲ្យបានលុះដល់ "មោក្ស=ការរួចស្រឡះ" គឺៈសុខក្តីបរ-សុទ្ធពិតប្រាកដ ហើយនឹងបានត្រឡប់វិលទៅកាន់ព្រហ្មវិញ ឬមួយទៅទីណាក៏ដោយ តែគោលបំណងនៅត្រង់ឲ្យអស់ការកើតតទៅ ៗ ដើម្បីឲ្យលុះផលប្រសើរនោះ មនុស្សទាំងឡាយត្រូវធ្វើដោយខ្លួនឯង មិនមែនត្រូវធ្វើដោយពិធីសែនបួងសួងបន់ស្រន់ទេពតាដូចកាលដើមទេ ៗ

សេចក្តីខាងលើបន្តិចនេះហើយ ដែលពួកអ្នកប្រាជ្ញច្រើននាក់ ខាងអឺរ៉ុបនិងទាំងអាស៊ី បានបបួលគ្នានិយាយថាពុទ្ធ-

សាសនាទិដ្ឋិសាសនាដទៃទេ៖ ប្រសូតចេញមកពីសាសនា ព្រាហ្មណ៍ ដែលមានបរិវាទណាក៏ដោយ យើងជាអ្នកកាន់ ពុទ្ធសាសនាគឺរាប់ខាងថា ពុទ្ធសាសនាកើតក្រោយមែន មើលទៅឃើញច្បាស់ជាមានស្នាបត់ខិតជាប់គ្នាបន្តុក ដែលអ្នក ដើរមុនគេស្ទួចមិនបានភ្ញាក់ឃើញទេ មានតែព្រះពុទ្ធមួយអង្គ ប៉ុណ្ណោះ ដែលរកស្ទួចឃើញ ហើយយកដោយក្រោយបំផុត បាន។ សេចក្តីនេះព្រះពុទ្ធទ្រង់ព្រះបរមាវីរៈមិនធ្វើតាមព្រាហ្មណ៍ ទេ ព្រះអង្គមានទ្រឹស្តីផ្សេងពីព្រាហ្មណ៍ស្រឡះ ដូច្នេះ យើង ហ៊ានពោលថា ពុទ្ធសាសនា មិនមែនជាលទ្ធិដែលប្រសូត ចេញពីសាសនាព្រាហ្មណ៍ដូចអ្នកផងពោលនោះទេ ព្រោះពិធី ព្រាហ្មណ៍ទ្រង់បានលះបង់ចោលអស់ហើយ កាលទ្រង់សិក្សា ពីតាបសទាំងពីរនាក់ ។

ដើម្បីឲ្យបានលុះផលខ្ពស់ផុត ឧបនិស្ស័យជាន់ចាស់បាន ពោលទុកថា មាន ២ ប្រការគឺ៖

១– ហៅថា "តបៈ" ជាវិធីចាស់តាំងតែពីសម័យវេទ តែមានការផ្លាស់ប្ដូរប្រែប្រួលមកហើយ ៗ ក្នុងសម័យវេទ ការបំពេញតបៈបានដល់ការសែនបួងសួង តែមិនមែនបួងសួងតាមធម្មតាទេ គឺត្រូវធ្វើយ៉ាងម៉ឺងម៉ាត់ ដោយព្យាយាមបំផុត ត្រូវអង្គុយសែនបួងសួងរហូតដល់ព្រឹកដល់ល្ងាច ឬ ច្រើនយប់ ច្រើនថ្ងៃ ៗ មួយទៀត ពាក្យថា តបៈ មានន័យថា "សេចក្ដីព្យាយាមប្រឹងប្រែង" ឯសេចក្ដីព្យាយាមប្រឹងប្រែងនេះផ្លាស់ប្ដូរទៅជា ៣ ជាន់គឺ:

ក – ខាងដើមសម័យវេទ ការប្រឹងប្រែងក្នុងបូជាដែលហៅថា "តបៈ" នោះ ដោយមានបំណងឲ្យទេវតាឃើញចិត្តថ្លើមខ្លួន ហើយករុណាប្រទានអ្វីមួយដែលយើងសុំ រួមសេចក្ដីទី គឺសុំករុណាពីទេវតា ៗ

ខ– ខាងចុងសម័យវេទ ការបំពេញតបៈ មិនមែនសុំករុ-ណាពីទេវតាទេ តែជាកិច្ចបង្ខំទេវតា គឺបើបានបំពេញតបៈ

ត្រឹមត្រូវហើយ ជឿថាទេវតាអត់ទ្រាំមិនបាន ត្រូវតែប្រទានអ្វីមួយតាមការសុំ ។ ការគរគំនរភ្លើងគគុលទៅមុខអគ្គិយេស្វីនស្វាធិការនា ជាវិធីរបស់តបៈក្នុងសម័យវានព្រុនវេទនោះ គេជឿថា ភ្លើងធំឡើងទៅបណ្តាលឲ្យក្តៅដល់ទេវតា ហើយទេវតាត្រូវអំណាចតបៈនោះ បន្តាប់ឲ្យព្រមឲ្យផលសម្រេចអ្វីមួយ តាមប្រាថ្នាអ្នកបំពេញតបៈ ។ ក្នុងវេលានេះ ពាក្យតបៈមានន័យថា "ក្តៅ" ។

គ– សម័យព្រាហ្មណៈ ពាក្យថា តបៈ ក៏នៅមានន័យថា "ក្តៅ" ដែរ តែមិនមែនធ្វើឲ្យទេវតាក្តៅទេ លទ្ធិគាត់នជាលទ្ធិខ្លួនឯង តបៈបែបគាត់ន មានន័យថា "ធ្វើខ្លួនឯងឲ្យក្តៅ" គឺការកាំងខ្លួនឯង ឬ កាំងកិលេសដុតបំផ្លាញរបស់ដែលមិនបរិសុទ្ធឲ្យអស់ចេញពីខ្លួន ឲ្យសល់នៅតែសេចក្តីបរិសុទ្ធិ ដើម្បីនឹងបានចូលទៅកាន់ព្រហ្មវិញ ។

មួយទៀត គំនិតនេះក៏កើតពីកម្មវៃរ គឺយល់ថា ព្រលឹង

វិលវល់កើតស្លាប់យ៉ាងនេះក៏ព្រោះកម្ម គឺផលអាក្រក់ដែលត្រូវទុក្ខក្នុងជីវិតនេះ ឬ ជីវិតពីអតីត ជាគ្រឿងសៅហ្មង បើបណ្ដោយតទៅ ទុក្ខដូចជាបណ្ដោយឲ្យវិលវល់កើតស្លាប់ទៀត ឬក៏យល់ថា កិលេសជាគ្រឿងសៅហ្មងដូចជាតណ្ហា កតៈជាហេតុឲ្យមនុស្សធ្វើអំពើអាក្រក់នេះ កើតមកពីផាសុកនៃរាងកាយ ឬកើតមកពីការប្រាថ្នាផាសុក វិញដែលរំលត់សេចក្ដីប្រាថ្នាទាំងនេះ គឺការទូន្មានកាយ កាលបើរាងកាយបានដឹងផាសុកហើយ សេចក្ដីប្រាថ្នា ដែលជាហេតុនៃកម្មនឹងមិនកើតឡើងទេ ។ កិលេសទាំងឡាយដែលមានហើយក៏អស់ទៅ ៗ ដូច្នេះ តបៈក្នុងសម័យព្រាហ្មណៈ ជារឿងទូន្មានកាយ ដែលពុទ្ធសាសនាហៅថា "អត្តកិលមថានុយោគ" ។

២– យោគៈ– យោគៈនេះកើតក្រោយតបៈ កើតដោយសង្ស័យថា ក្រែងតបៈមិនបានផលល្អគ្រប់គ្រាន់ ។ លទ្ធិយោគៈ បញ្ញត្តខុសពីតបៈ លោកឧត្តម ស្រុស អធិប្បាយ

ថា ការផ្សំគ្នានៃតបៈនិងយោគៈនេះ គឺតបៈ ជាកិច្ចខាងកាយ យោគៈជាកិច្ចខាងចិត្ត តបៈទូន្មានកាយ យោគៈទូន្មានចិត្ត ។ តបៈគេជឿថា បើទូន្មានកាយឲ្យច្រើន នឹងកើតតែបានល្អ ។ យោគៈគេប្រកាន់ថា ត្រូវរក្សារាងកាយទុកដោយប្រពៃបំផុត ទើបទូន្មានចិត្តបាន ។ យោគៈ ប្រែថា គ្រឿងកានបង់គ្រៀក ដូចបង្ហៀរបង់សេះឲ្យដើរទៅតាមប្រាថ្នាខ្លួន កាលបើយកពាក្យយោគៈនេះ មកប្រើខាងចិត្ត ក៏បានសេចក្ដីថា ចិត្តមនុស្សនេះ មានឫស្សដូចជាសេះដែរ លុះយោគៈនេះជាគ្រឿងកានបង់គ្រៀក ឃុំគ្រងឲ្យសេះគឺ ចិត្តមនុស្សនេះ ទៅតាមអំពើខ្លួនបាន ។ ដូច្នេះ ឧបនិបទ ជាការផ្ដើមគំនិតសសៀរចូលទៅរកចិត្តហើយ ។

លោក ឧត្ត ស្រុស អធិប្បាយតទៅថា លទ្ធិយោគៈបានឲ្យអំណាចបំផុសស្មារតីដល់អ្នកហ្វឹកហ្វឺនហាត់ប្រតិបត្តិ តែគោលបំណងយោគពិតនោះ មិនមែនត្រង់អំណាចចិត្តនោះ

ទេ នៅត្រង់ពាក្យថា "យោគ្យ=ការរួចស្រឡះ" គឺការចូល ទៅកាន់ព្រះព្រហ្មណ៍ ។ មានវិធីហាត់ច្រើនបែបណាស់ក្នុង យោគៈ ដោយចំពោះ កាយបរិហារ គឺធ្វើកាយឲ្យមានសុខ ភាពល្អ ឲ្យចាំមួនដល់ចិត្ត មាន[illegible]វត្ថុយ ហាត់ដង្ហើមចេញចូល វិធីរៀបគំនិតមិនឲ្យពាក់ព័ន្ធនឹងអារម្មណ៍ពីខាងក្រៅ ឲ្យចិត្តជា សមាធិ ហើយឲ្យចិត្តដឹងថា ខ្លួនឯងនឹងរួចចេញពីលោក ដែល[illegible]ដោយ[illegible]នេះ ហើយចិត្តចូលទៅ កាន់លោកនៃព្រហ្មហើយ ។

អ្នកប្រាជ្ញអឺរ៉ុបម្នាក់ទៀតឈ្មោះ អុលដឹនប៊ើគ (Oldenberg) អធិប្បាយថា យោគៈគឺការធ្វើឲ្យស្ងប់ស្ងាត់ ហើយរក្សាទុកឲ្យឃើញភាពដទៃ ១ ដែលមិនមែនជាភាព ប្រក្រតី ព្យាយាមកំចាត់បង់នូវគ្រឿងប៉ះពាល់រាងរបស់ដែល ប្រព្រឹត្តទៅបាន នឹងប្រព្រឹត្តទៅមិនបាន កំចាត់អ្វីមួយដែល ជាសមត្ថភាពរបស់ចិត្តឲ្យរស់ចេញទៅ ឲ្យដឹងខ្លួនថាខ្លួនឯង

ទៅរលឹកពុតសភាវធម្មជាតិនៃលោក ព្រមទាំងទៀងទៅនៅគុណ លោកណាមួយទៀត ដែលរស់ជាន់លោកនេះហើយ ។

លោកុត្តរធម៌ សាស្ត្រាចារ្យខាងទស្សនវិជ្ជាបំពេញ ជាប្រធានាធិបតីព្រះទេសនា អធិប្បាយថា លោកៈ ជាវិធី បាកចិត្តឲ្យតាំងនៅក្នុងវិន័យដ៏ប្រសើរ ជាលទ្ធិដែលមានគោល សម្បូរណ៍ក្នុងខ្លួនឯង មិនជាប់ទាក់ទងជាមួយទេវតាអង្គណា មួយទេ ព្រោះគេប្រកាន់ថា ចិត្តជាធម្មជាតិបរិសុទ្ធ ដោយធម្មជាតិ គ្រឿងសៅហ្មងទាំងឡាយដែលមាន ក៏កើត មានជាខាងក្រោយទេ សេចក្តីបរិសុទ្ធនៃចិត្ត មិនដាច់សាប ទេ មិនត្រូវធ្វើអ្វីទេ ព្រោះបរិសុទ្ធស្រាប់ហើយ គ្រាន់តែ ជម្រះលាងគ្រឿងជំពាក់ គ្រឿងប្រឡាក់ឲ្យអស់ចេញទៅ តែប៉ុណ្ណោះ ក៏បានការស្រេចហើយ បើលាងជម្រះឲ្យ ស្អាតហើយ ចិត្តក៏នៅតែជាចិត្តបរិសុទ្ធដដែល ចិត្តពិតប្រាកដ នោះឯងគឺលោកៈ, ចិត្តពិតប្រាកដនោះឯង គឺការបួលទៅ

ផល់ព្រាញ ៗ គំនិតលោកកេចក្រើម្ចនេះ ជាគំនិតថ្មីដកស្រង់យកពុទ្ធភាសិតមកប្រើ ដើម្បីឲ្យឃើញថាអ្វីៗ ក៏ជារបស់លទ្ធិហិណ្ឌូដែរ ដូចពុទ្ធភាសិតថា បកស្សរមិតំ ភិក្ខវេ ចត្តំ លោកយកប្រើក្នុងប្រយោគភាសាលីនេះ ៗ

X

X X

# សង្ខេបពណ៌នា

តាមការសង្កេតទូទៅ យើងបានឃើញថា ពិភពនៃប្រជាជនសកលលោក មានមុខងារច្រើនប្រការណាស់ មុខងារខាងផ្លូវចិត្ត សង្គមកិច្ច មុខងារចំពោះបុគ្គលម្នាក់ ៗ ជាដើម មុខងារទាំងអស់នេះ ដោយពិត ច្រើនតែកើតចេញមកពីលទ្ធិសាសនា ៗ ការសង្កេតជួបពេលមកនេះ ឃើញមានសេចក្តីពិតច្រើនណាស់នៅក្នុងកាយធម៌វណ្ណា ៗ ដូច្នេះ សាសនាជាមេបង្កើតមុខងារ ៗ មុខងារនេះ កើតបានទៅជាទំនៀមទម្លាប់, ទំនៀមទម្លាប់ក៏កើតចេញទៅជាប្រពៃណីនិយមតទៅទៀត ៗ នេះហើយជាបាទសារវត្ថុនៃកត្តារបស់កាយធម៌វណ្ណាទាំងមូល ៗ

តទៅ យើងត្រូវសិក្សាលទ្ធិសាសនាវណ្ណាតាមទិដ្ឋភាពខាងផ្លូវចិត្ត និងខាងសង្គមកិច្ច ៗ ក្នុងការផ្តើមសិក្សា យើងត្រូវយកស្ថាប័ននៃសាសនៈវណ្ណាពីបុរាណមកពិចារណា ទើប

យើងនឹងអាចយល់នូវលក្ខណៈនៃសង្គមឥណ្ឌាបានដោយច្បាស់លាស់ គឺយើងត្រូវយកប្រពៃណីបុរាណ ដែលជាអាយ៌-ធម៌នៃវេទ្ធកសី គឺជនជាតិមុទ្ធប្បព្រាវិឌ ដែលជាអ្នកដើមកំណើតប្រទេសឥណ្ឌាព្រមទាំងប្រពៃណីអាយ៌ធម៌ដែលទើបមកថ្មី មកទុកជាវត្ថុធាតុសម្រាប់ពិចារណា តែកិច្ចការទាំងនេះពិបាកពេកដូចជាហួសវិស័យនឹងធ្វើទៅបាន ដោយព្រោះហេតុតែយើងមិនមានឯកសារគ្រប់គ្រាន់ ៗ

យើងបានដឹងថា ប្រទេសឥណ្ឌាខាងទក្ខិណាបថ មិនបានទទួលយកអាយ៌ធម៌ថ្មី ដែលជារបស់អាយ៌ន នៅខាងអារ្យាបថច្រើនប៉ុន្មានទេ ៗ យើងអាចរកឯកសារបុរាណក្នុងកាលនោះបានខ្លះនៅក្នុងបច្ចុប្បន្នកាលនេះដោយអាស្រ័យឯក-សាររបស់សង្គមជនជាតិ ព្រាវិឌ ដែលនៅសល់ខ្លះ ៗ ប៉ុន្តែការនេះ ហាក់ដូចជាចូលក្នុងសេចក្តីព្រហើនបន្តិចទៅហើយព្រោះហ៊ាននិយាយដល់សភាពសង្គមជនជាតិឥណ្ឌាមុនអាយ៌ន

ដែលហៅថា ទ្រាវីឌ កាលពី ១៥០០ ឆ្នាំ ឬ ២០០០ ឆ្នាំមុន គ្រិស្តសករាជ ។ មួយទៀតជនជាតិ ទ្រាវីឌ **នេះ ពីបុរាណ** មិនមានគោលអ្វីជាលាយលក្ខណ៍អក្សរល្មមសិក្សា**បានទេ** មាន**តែចំនៀម** ដែលមាននៅសល់ហើយជាប់លាយ**ទៅក្នុងគម្ពីរវេទ** ខ្លះប៉ុណ្ណោះ ។ ដោយការមិនសូវសម្បូណ៌ឯ**កសារនេះ**ឯង យើងត្រាន់តែពិចារណាគោលលទ្ធិ ឥណ្ឌា មុនគម្ពីរ**វេទដោយ** សង្ខេប ។ ការសិក្សាសង្គមឥណ្ឌាឲ្យបានយល់ គឺត្រូវតែ សិក្សាគម្ពីរវេទនេះផង ព្រោះវេទជាបាទនៃសង្គមឥណ្ឌា ។

វេទ ប្រែថា "ការចេះដឹង" ជាឈ្មោះគម្ពីរសក្ដិសិទ្ធិ របស់ព្រាហ្មណ៍មាន ៤, តែកាលដើម មានតែវេទ ៣ ទេ ដែលគេហៅថា "ត្រៃវេទ" ។ ក្រុមវេទមួយ ៗ ហៅថា "សំហិតា" ប្រែថា "ការប្រមូល, ការចងក្រង ឬ ក្រុម" គឺ:

១– ឫគ្សំហិតា ឬ ឫគ្វេទ

២-សាមសំហិតា ឬ សាមវេទ

៣-យជុះសំហិតា ឬ យជុវេទ

៤-អថវ៌សំហិតា ឬ អថវ៌វេទ

កាលបើគេនិយាយថា "ត្រៃវេទ" គេបន្ថយ "អថវ៌-វេទ" មួយចេញ ព្រោះវេទនេះជាគម្ពីរថ្មី ដែលគេបន្ថែមក្នុងកាលជាន់ក្រោយ ៗ គម្ពីរព្រះសាសនា ហៅគម្ពីរវេទទាំង ៤ នេះថា ឫគ្វេទ សាមវេទ យជុវេទ និង អថវ៌វេទ ៗ ក្នុងគម្ពីរវេទមួយ ៗ មានគម្ពីររងមួយ ៗ ជួយពន្យល់ចំនួនដូចជាអដ្ឋកថាព្រះត្រៃបិដកយើងដែរ ហៅថា ព្រាហ្មណៈ អារណ្យកៈ ឧបនិសទ មួយ ៗ ជាប់នឹងគម្ពីរវេទមួយ ដូចនៃឥតរេយៈ ព្រាហ្មណៈ ជាប់នឹង ឫគ្វេទ ; ឆន្ទោគ្យ ឧប-និសទ ជាប់នឹង សាមវេទ ដូច្នេះជាដើម ។

"ព្រាហ្មណៈ" ជាគម្ពីរមួយនិយាយពីវិជ្ជាសក្តិសិទ្ធិរបស់ព្រាហ្មណ៍មាន ២ ប្រការគឺ វិធី (Prescriptions) ១,

អដ្ឋកថា (Explications) ១, ហើយមាន "សាខា" ឬ "លទ្ធិ" (Ecoles) ច្រើនគណៈទៀត ។

"អារណ្យកៈ" ប្រែថា "អត្ថបទនៅព្រៃ" និយាយពីការស្មាក់កំបាំង (រហស្ស) ដែលត្រូវរៀននៅឆ្ងាយពីគេ ក្រៅពីពួកគណៈ គឺនៅក្នុងព្រៃដាច់ជន ។

"ឧបនិស័ទ" ប្រែថា "អង្គុយជិត" គឺជាបទដែលត្រូវតែងតាមមតិបទព្រាហ្មណៈ នៃអារណ្យកៈ ។ ល ។

វេទាង្គៈ ប្រែថា "អង្គនៃវេទ" ជាវិជ្ជាអធិប្បាយពន្យល់វេទមាន ៦ ប្រការ គឺពន្យល់ពី សិក្សា (La Phonetique), កល្បៈ (Le Rituel), វ្យាករណៈ (La Grammaire) និរុត្តិ (L'Etymologie), ឆន្ទ (La Métrique), ជោតិស (L'Astronomie) ។

វេទាង្គនេះ សម្រាប់រៀនគឺត្រូវរៀនឲ្យចាំមាត់ ហើយត្រូវមានគ្រូពន្យល់ទៀត ។ ឯក្រៅពីសូត្រ និយាយពីការប្រមូល

ទាក់ទាមការរៀនដាល់ដាប់យជ្ញៈ, គ្ឫហ្យសូត្រ និយាយពីពិធីប្រសិទ្ធិការ ឬ ផ្ដើមផ្ដល ហៅថា «សំស្ការៈ ការធ្វើឲ្យបានប្រសើរ, ប្រសិទ្ធិ» ។ គម្ពីរទាំងពីរនិយាយពីកល្បៈ ហៅថា កល្បសូត្រៈ ។ សូត្រៈដទៃទៀតនិយាយពីច្បាប់ ទាងសីលធម៌ ឬ ទាន់សាសនា ហៅថា ធម៌សាស្ត្រ ។ នៅក្នុងក្រុមគម្ពីរលោកកាត្យាយន (Kàtyayana) មានតែស្រៅតសូត្រ និង សុល្វសូត្រៈ, នៅក្នុងក្រុមគម្ពីរលោកអស្វលាយន (Acvalàyana) មានតែស្រៅតសូត្រ និង គ្ឫហ្យសូត្រ ។ ឯក្រុមគម្ពីរលោកអាបស្តម្ព (Apastamba) និង លោកបោធាយន (Baudhàyana) ទើបមានស្រៅតសូត្រ, គ្ឫហ្យសូត្រ, ធម៌សាស្ត្រ និង សុល្វសូត្រ ប្រមូលទាំងកល្បសូត្រ ៤ គម្ពីរទៀតផង ។ ការភ្ជាប់ជាមួយនេះមិនបានដាក់សព្វគ្រប់ទេ(១) ។

---

១— សូមមើលតារាងភ្ជាប់នៅភាគក្រោយបង្អស់ ។

ការបូជាក្នុងគ្រួសារៈ— ពិធីបូជា(១)ដែលមានក្រោមក្នុងគម្ពីរឫគ្វេទ តពីតំណពូជមួយទៅពូជមួយទៀត រាប់តាំងផ្ដើមមកហើយ មានច្រើនបែបណាស់ មិនមែនមានតែបែបមួយជាប់រហូត គ្រប់កាលវេលាមកដល់បច្ចុប្បន្នកាលនេះទេ មានបែបផ្សេង ៗ កើតច្រើនហើយមានការផ្លាស់ប្ដូរ ឬមានការផ្ទុយខុសពីគ្នា ឬក៏មានការប្រែប្រួលទៅតាមលទ្ធិរបស់ខ្លួន ទៅតាមគ្រូ ទៅតាមកាល កើតបានទៅជាប្រពៃណីផ្សេង ៗ ក្នុងគម្ពីរក៏មានប្រាប់ដែរថា មានពិធីខ្លះគេបោះបង់ចោលលែងប្រតិបត្តិតាមទៅហើយផង ។ មួយទៀតមានសេចក្ដីថា ក្នុងវេទមានសេចក្ដីបង្គាប់ឲ្យធ្វើដូច្នេះ ដល់មកក្នុងសូត្រក៏ស្រាប់តែប្រាប់ថាឲ្យធ្វើដូច្នោះទៅវិញ ឈ្មោះយជ្ញភាណ្ឌ ឬ ហោម-ភាណ្ឌ គ្រឿងឧបករណ៍សម្រាប់ធ្វើការបូជានៃពិធីសោមៈនិង

១- សេចក្ដីពិស្ដារ មើលសៀវភៅ Inde classique T. I., ពីទំព័រ ៣៤៨ (Rituel) តទៅ ។

ឈ្មោះអ្នកបូជា ហោត្រ ឬ ហវិរ៉ុន គឺមានផ្លាស់ប្តូរដែរ ៗ ពិធីបូជានោះមានបែបបទច្រើនណាស់ លោកអុលដេនប៊ែរគ៍ (OLbenberg) និយាយថា "មុខងារនៃព្រាហ្មណ៍និងបុរោ-ហិត ដែលមានក្នុងគម្ពីរវេទ ហើយមិនស្របគ្នាតាមក្បួនវិធីពិធីទេ លោកប៊ែរហ្គេញ (Bergaigne) និយាយថា "ពិធីបូជា" មានកំណត់ក្នុងគម្ពីរវេទ, រីឯលោកហ៊ីល្លប្រែន (Hille Brandt) និយាយថា គម្ពីរឫគ្វេទ មានការផ្លាស់ប្តូរពិធីបូជា ៗ លោកហែរតែល (Hertel) និយាយថា ពិធីអាប្រ៊ី (Apri) គឺធ្វើក្នុងពិធីបុណ្យចូលឆ្នាំថ្មី ដែលមានការជាប់ទាក់ទងនឹងការឈប់ដើរនៃព្រះអាទិត្យ ក្នុងសិសិររដូវតែប៉ុណ្ណោះទេ" ដូច្នេះជាដើម ៗ

ពិធីបូជាជាកិច្ចនៃអ្នកបួស; ការធ្វើបូជាហៅថា យជ្ញក្រិយា, យជ្ញ ឬ ហោមៈ ( Oblation ) ប្រែថា ការបោះគ្រឿងបូជា ហវិស (យជ្ញទ្រវ្យៈ, ហវ្យៈ គឺ សប្បិ ហោមៈ

ទីរៈ គ្រាប់ស្រូវ) ឬ ពលីទៅក្នុងភ្លើង ឬបូជាចំពោះទេវតា ដែលជាការបូជាក្នុងគ្រួសារ (Culte familial) ដើម្បីឲ្យកើតសេចក្តីសុខ សេចក្តីចម្រើន មានសុខភាព មានអាយុវែង សម្បូរណ៍សត្វពាហនៈ ព្រមទាំងឲ្យបានកូនប្រុស តែទិយ ដែលគោលបែកនេះ មិនប្រព្រឹត្តទៅតាមសភាពពិតនៃពិធីក្នុងគម្ពីរវេទទេ ៗ បើតាមលោកគេថ (Keith) ដែលជាអ្នកប្រ-កាន់តាមពិធីបូជានោះ យើងនឹងឃើញថា សេចក្តីបកស្រាយនៃលោកហ៊ូប៊ែរ (Hubert) និងលោកម៉ូស្ស (Mauss) ត្រឹមត្រូវតាមគម្ពីរព្រាហ្មណ៍ពិតមែន គឺថា ពិធីបូជាជាការធ្វើឲ្យកើតភក្តិសក្តិសិទ្ធិ សម្រាប់ធ្វើបុគ្គលដែលជាឥតរជន (Profane) ឲ្យបានទៅជាបុគ្គលសក្តិសិទ្ធិ (Sacré) បានសេចក្តីថា ផ្លាស់ឲ្យកើតទៅជាធម្មិកបុគ្គល (Personne morale) ដោយអំណាច

៨. នៃពិធីនេះ ៗ ឯអ្នករងគ្រោះ (Victime) មនុស្ស ឬ សត្វ ដែលត្រូវគេយកទៅធ្វើជាគ្រឿងបូជា (យជ្ញទ្រព្យ, ហវ្យៈ

ពលិ) នោះ ត្រាន់តែជាការសម្រេចកិច្ច ឬ គ្រាន់តែជាការបន្ត ពូជាសួ ឬគឺជាជាគមនាគមន៍រវាងអ្នកជា ក់តជន និង បុគ្គលសក្តិសិទ្ធិតែប៉ុណ្ណោះ, រីអ្នកបួសទើបទុកជាអាណត្តិកជននៃអ្នកបូជា ( ហរិចេន ឬ ហោត្រ ) ព្រមទាំងទុកជាប្រតិភូនៃទេវតាបានទៀតផង ។

ឯពិធីបូជាគ្រប់បែប ត្រូវមានសូត្រស្តី (Prière) ជាដរាប, សូត្រនិង ១ តាមរូបមន្ត « យជុស៍ », សូត្រផ្ទាល់ ១ ហៅថា « ប្រៃសះ » ហើយឲ្យមានពាក្យថា « ឧមិ » លាយឡំបន្ថែម ។

គ្រឿងបូជា (យជ្ញទ្រវ្យៈ, ហវ្យៈ ឬ ពលិ) ត្រូវបោះពាក់កណ្តាលទៅក្នុងភ្លើង (អគ្គិ) ពាក់កណ្តាល ត្រូវបានទៅជាអាហារនៃអ្នកបូជាដែលហៅថា ហោត្រ (Officiant) ដែលមានជីវិតទុកជាទេវតា, ឯអាហារក៏ទុកដូចជារបស់ទិព្វដែរ ។ រីឯផលគ្រឿងបូជា គឺជាផលិតផលដែលកើតបានមកពីស្រែចំការ

គឺទឹកដោះគ្រប់បែប ដូចជាសប្បិ (កក ឬ ជាដុំ) បញ្ញោតិ (អង្ករដែលធ្វើជានំ) ។ សត្វដែលគេសម្លាប់បូជា ហៅថា បគុពន្ធ ឬ បគុហារ្យ, វត្ថុដែលត្រូវបូជាក្រៅពីសត្វមានជីវិត ហៅថា ឥស្តិហារ្យៈ ។ សត្វដែលត្រូវបូជាគឺ ពពែ គោ លា វ្ក ។ វ្កសម្រាប់បូជា ចំពោះវក្សសៈ ។ ការបូជាសេះ ហៅថា អស្វមេធៈ ជាពិធីធំមួយ, ឯការបូជាមនុស្ស គេទុកជាពិធីធំ បន្ទាប់វើតមកទៀត ហៅថា បុរុមេធៈ ។ គម្ពីរ អត្ថបយនៈនិយាយថា សត្វដែលគេត្រូវសម្លាប់កាលពីដើមមាន ដល់ទៅប្រាំ, មានមនុស្សម្នាក់ គេកាត់យកក្បាលទាំង ៥ នេះទៅលាក់ទុកក្នុងកំពែងថ្ម ហើយគេបោះខ្លួនទាំងប្រាំទៅ ក្នុងទឹក ។ មនុស្សនេះ ទោះជាព្រាហ្មណ៍ឬក្សត្រិយ៍ គេ ត្រូវទិញមកដោយតម្លៃ ១០០០ គោញី ឬក៏ ១០០ សេះ មុន សម្លាប់នេះធ្វើដូចសេះដែរ គឺគេលែងឲ្យដើរទៅតាមចិត្តមួយឆ្នាំ បានគេសម្លាប់, សម្លាប់ហើយព្រះអគ្គមហេសីស្តេចត្រូវទៅផ្ទំ

នៅក្បែរភ្នំនោះ ។

សោមៈ ជាទឹកស្រវឹង (ផឹកហួសកំណត់មានគ្រោះ) ធ្វើពីរុក្ខជាតិ, អ្នកប្រាជ្ញយល់ថាជារុក្ខជាតិមួយដែលហៅថា Asclé-piade (លោក Jogeç Chandra Ray ថា Asclépias acida: Chanvre ; លោក Aurel Stein ថា Rhubarbe sauvage ) ។ ពិធីធ្វើស្រា "សោមៈ" នេះ គេត្រូវទិញរុក្ខជាតិសោមៈដោយតម្លៃគោមួយ ហើយត្រូវដាក់ទោសដល់អ្នកលក់ឲ្យដែរទៀតផង ត្រូវដាក់រថដឹក ឬ ទូលលើក្បាលរួចជាក្បួនហៅយកមក ផងទឹកយកមកលាយកិនដើមសោមៈយកជាតិទឹក ហើយច្រង យកទឹកដមមកដាក់ក្នុងថាង លាយទឹក ទឹកដោះ ជួនកាលលាយទឹកឃ្មុំផង ។ គេសង្ស័យថា ប្រហែលជាសោមៈ ជាភេសជ្ជៈប្រជាជនទូទៅ បានជាគេប្រើជាធម្មតា ព្រោះភេសជ្ជៈដែលគេទុកជារបស់ថោកទាបហើយគេហាមខ្លះផងនោះគឺសុរា ដែលគេបិតយកជាតិស្រ-

ជាតិវង្ស ។ ប្រើមួយដងមួយកាលតែក្នុងពិធី ពិសេស ទៅក្រោមទី ប៉ុណ្ណោះទេ ។

អ្នកធ្វើការបូជាសម្រាប់ខ្លួនឯងហៅថា យជមាន: បើព្រះកជា ជាយជមាន: គឺពួកមហាក្សត្រិយ៍ ព្រាហ្មណមហាសាល ជាអ្នកជាន់ខ្ពស់ក្នុងវណ្ណៈទាំង ៣ បើធ្វើយ៉ាងឯកជន មានភរិយាជាអ្នកជួយផង ប៉ុន្តែការសំខាន់នៅលើបុរោហិត ។

អ្នកចាត់ការបូជាហៅថា ហោត្ឫ (Officiant) ជាពាក្យពីបុរាណកាល (អវេស្ថ: Zaoter= អ្នកបួស) ដែលមានក្នុងគម្ពីរឫគ្វេទ ប្រែថា "អ្នកបោះ ឬ ចាក់" យជ្ញ ឬហោម លោកហែតែល (Hertel) ប្រែថា "អ្នកហៅ" (Appeleur) ជាអ្នកសូត្របួងសួង តាមគាថាក្នុងឫគ្វេទ ។ ហោត្ឫនេះ កាន់មុខងារជាជាប់ខាងក្នុងពិធីយជ្ញ ដែលត្រូវអ្នករៀបចំជើងក្រានអគ្គិប្រើប្រាស់យជ្ញការណ៍ ឬ ហោមការណ៍ (Instrument d'oblaton) បោះ ឬ ចាក់គ្រឿងបូជាយជ្ញទ្រៀ

ឬ ហវ្យ (Objet servant au sacrifice) ។ ការថែរក្សា ឬសំរាកគវេទី គឺភ្លើងក្រានអគ្និ ហៅថា អគ្និធ (Agnidh) របកក្លាយទៅជាអាគ្នីធ្រ: (Agnidhra) ប្រែថា "អ្នកបង្កាត់ភ្លើង" ។ ការបូជាភ្លើង ហៅថា ហោត្រ (Hotra) ឬ អគ្និហោត្រ (Agnihotra) ធ្វើនៃអ្នកចាត់ការម្នាក់បាន គឺព្រាហ្មណ៍អធ្វយ៉ុ (Adhvaryu) តែពិធីបូជា សោម: ទាល់តែមានគ្នា ១៦ (ឬ១៧) នាក់ ទើបធ្វើបាន ហើយចែកជា ៤ ក្រុមទៀត នៅក្រោមអធិបតីភាព នៃហោត្រអធ្វយ៉ុ ឧទ្គាត្រ និង ព្រាហ្មណ៍ ។

ទីឋានបូជា.— គម្ពីរវេទនិយាយថា មិនបាច់មានទីឋាន ៗ គេធ្វើក្នុងផ្ទះឬវិហារ ទីវាលមានស្មៅក៏បាន គេតាំងភ្លើងក្រាន ៣ កន្លែង ទីកន្លែងនេះរៀបចំស្រេចសម្រាប់ព្រាហ្មណ៍យជមាន: និងភរិយា ឲ្យមានទីក មានដំបូក ។ ទីកណ្តាលគេតាំងវេទី (Autel) ទ្រង់ទ្រាយ ៤ ជ្រុងទ្រវែង ជ្រុងខុប

បត្តិប ជាកន្លែងដែលគេសម្រាប់ដាក់តម្កល់គ្រឿងបូជា ល.ទ ធ្លាប់ស្មៅដេរជាសសេនៅជុំវិញ ( ពហ៊ីស៍ (អវេស្តៈ) ពារស៊ីន. ពសិស៍ “ខ្នើយ ”) ដើម្បីទុកឲ្យទេវតា គួរឲ្យគង្គ័យ ហើយបរិភោគគ្រឿងបូជា ៗ វេទីនោះ ជួនកាលធ្វើពីថ្ម មានទំហំធំទូលាយដែរ ។

បើធ្វើពិធីបូជា សោមៈ ត្រូវមានមហាវេទី (Mahavedi) ទ្រង់ព្រាយ៤ជ្រុងក្តាយ ដើម្បីទទួលរថសម្រាប់សោមៈ ហើយ មានឧត្តរវេទីមួយទៀត ព្រមទាំងមានកេងសម្រាប់ជា ធិប្ប គឺកន្លែងជ្រកកូនទៅនៃអ្នកដាក់ការបូជាផង ពិធីបូជាមាន ច្រើនណាស់តទៅទៀត, ក្នុងទីនេះនិយាយមិនអស់ទេ ។

ពិធីមហាវ្រត.– “ មហាព្រត ” ជាពិធីបញ្ចប់ការដើរ នៃព្រះអាទិត្យក្នុងសិសិររដូវ ( វស្សានរដូវ តាមលោកហ៊ីល្លេ-ប្រ៊ិន), ឯលោកហៅវ័រ (Hauer) និយាយថាជាការគាប់ កំបាំងមួយបែប ដែលគេធ្វើពេញទាំងប្រទេសឥណ្ឌាបុកណា

(Classique) មានភ្លេង ស្គរ ខ្លុយ មានរហាត្បជិះទោង (Escarpolette) យោល, មានជនការយ័ន និងជនគ្រូព្រះ ដណ្ដើបស្បែកពណ៌សរនិមួល មានកុមារីកំ ៗ លោកគេថ (Keith) និងលោកហៅវ៉េ យល់ថា ជាការធ្វើឲ្យកើត ចំរុងចំរើន ៗ ចុងបំផុត ទើបគេធ្វើជាក្បួនទំលាប់សំរាប់ជា សិរីសួស្តី ហើយធ្វើពិធីស្នានៈនៅថ្ងៃនោះ ៗ ទាំងអស់ នេះ កើតចេញមកពី "យាត្រា" បុរាណ (Classique) ។

ពិធីកំដរបោយ.— កំដរបោយ "ការពីកកេសម្ពុះភ័យ-ផុន:" ។ ពិធីនេះកំចេញមកពីពិធីសោមៈថ្ងៃ មានការ បរេថ ១៧ ថ្ងៃដោយសេះច្រើន បញ្ចុះអ្នកធ្វើការបូជាហើយ បរទៅតាមផ្លូវជាគន្ទង់ ដែលគេបាញ់សរឲ្យចរទៅ ១៧ សរ ព្រាហ្មណ៍ម្នាក់ជិះនៅកណ្ដាលរថ មានគន្លឹបក្រម៉ូយនៅលើផន ក្ដាន ហើយគេបង្វិលគន្លឹបក្រនោះឲ្យវិលតាមផ្លូវដែលបរេថ ទៅ ។ ចុងបំផុត មានពិធីឡើងទៅកាន់ព្រះគាថក្យ, ពិធីនេះ

អ្នកធ្វើការបូជាព្រមទាំងភរិយា ត្រូវឡើងទៅកាន់កំពូលក្រឡើ មេឃ ដែលជារូបភាពនៃសួគ៌ ហើយដែលគេបង់ទៅ បណ្ដោលខ្ពស់សក្តិសិទ្ធមួយ ៗ ពិធីវាជបេយ:នេះ មានគេ រិះគន់ច្រើន ដូចពិធី "រាជសូយ" ដែរ គេធ្វើពី ១ ថ្ងៃទៅដល់មួយឆ្នាំក៏មានដែរ ៗ នេះជាពិធីធ្វើឲ្យបានចំរុង ចម្រើនដែរ ៗ (Przyluski) និយាយថា ពិធីនេះ ដូចពិធី បូជាសេះនៃជនជាតិបាប៊ីឡូនី (Babylonie) ដែរ ៗ

ពិធីរាជសូយ:— រាជសូយ "ព្រាក្ដាភិសេក" ក៏ចេញ ពីពិធី "សោម:"ដែរ ប៉ុន្តែមិនជាបុណ្យពេកទេ ៗ ព្រាក្ដា-ភិសេកដោយការស្រោចទឹក គឺហោត្រម្នាក់ជាអ្នកកំណាន់ក្រស្ត ទាំងឡាយមកស្រោចស្រប់ព្រះរាជា ពោលយកទឹកផ្សេង ៗ ដោយ ទឹកសម្បូរទឹកឃ្មុំ ដែលដាក់ក្នុងភាជន៍ជាវិការនៃឈើឧទុម្ពរ ព្រះ រាជាប្រថាប់នៅលើបល្ល័ង្កឈើឧទុម្ពរនេះដែរ តែត្រូវយក ស្បែកខ្លាគ្របពីលើ, នាម៉ឺនមុខមន្ត្រីនៅព័ទ្ធជុំវិញ, រឿងនេះជា

រឿងគួរពិតពិលរមិលមើលណាស់ ព្រះរាជាក្នុងគ្រើជាអ្នកលប ចូលទៅដណ្តើមហ្វូងគោញីដែលជារបស់ផងញាតិណាមួយនៅ ជិតខាង (សេចក្តីប្រែមួយទៀតថា ស្តេចលបចូលទៅយករបស់ ទ្រព្យញាតិជិតខាង) ហើយទ្រង់ប្រទានទ្រព្យឲ្យម្ចាស់ដើមវិញៗ នេះគឺជាទិដ្ឋភាពទាំងពីរនៃការប្រាថ្នាភាពជាស្តេច គឺការដណ្តើម រាជ្យ និងអភិរាជ្យ ។ មានកិច្ចការផ្សេង ៗ ទៀតសម្រាប់ បញ្ចប់ពិធីនេះ គឺព្រះរាជាប្រថាប់នៅលើស្បែកខ្លា ក្រសាល បាស្កាជាមួយអ្នកឃុំ បើបាញ់ត្រូវសង់ជាគោញី ។ ឯយញ្ញទ្រព្យ គឺ ទក្ខិណៈ ត្រូវបនុស្ស១០ម៉ាក់ ផឹកសុរាជាមួយគ្នា ដោយ តែង១០ដៃ ។ ឡើងទាន់ទៅនៃរាជសូយៈនេះ មានតម្លៃច្រើន ហួសប្រមាណពេកណាស់ ជួនកាលមានដល់ទៅ ២៤០.០០០ គោ រ៉ុតិបាន ។

អស្វមេធៈ.- អស្វមេធ «បូជាសេះ» ជាពិធីបូជាមួយធំ ស រៀកក្នុងវិធីវេទ ព្រោះជាការសំដែងតេជានុភាពនៃព្រះរាជា

ដែលទ្រង់មានជ័យ ៗ ពិធីនេះមានកំណត់ ៣ ថ្ងៃ តែការរៀបចំត្រូវប្រើវេលា ដល់ទៅមួយឆ្នាំ ឬពីរឆ្នាំ ហើយគេតែងតែធ្វើក្នុងខែកុម្ភៈ-មេសា ៗ ក្នុងពិធីនេះ មានហោត្រ ៤ នាក់ ព្រះអគ្គមហេសី ៤ អង្គ ព្រមទាំងព្រះកជបរិពារ ៤០០ នាក់ មានប្រជាជនច្រើនអនេក ៗ

លុះបានធ្វើកិ (Kite) ច្រើនបុនហើយ គេនាំយកសេះមួយមក ដែលជាពាហនៈដ៏មានតម្លៃ ហើយគេបោះទ្រោចក្នែមួយទៅក្រោមជើងសេះ ព្រមទាំងមានធ្វើហោមផ្សេង ៗ ទៀត ទើបគេលែងសេះឲ្យដើរទៅតាមទំនើងរាំ ជាមួយនឹងសេះដទៃទៀតចំនួន ១០០, មានពលមនុស្សកម្លោះ ៤០០នាក់ ដើរតាមក្រោយសម្រាប់ថែរក្សាព្រមទាំងប្រយុទ្ធចំពោះសត្រូវដែលមកយាយីទៀត ៗ នៅឯទីលានពិធីបូជា មានការនិយាយរឿងព្រេង ស្ដាប់គេដេញពិណ ធ្វើហោម ៗ មួយឆ្នាំ សេះត្រឡប់មកវិញ ទើបមានធ្វើពិធីសម្លាប់សត្វបូជា, មានធ្វើពិធី

ទិក្សា (ពិធីសារពើ) ១២ ថ្ងៃ, មានការរាស់វេទី តមកគេធ្វើពិធី ឧបនិប័ទ ១២ ថ្ងៃ, ពិធីសោម ៣ ថ្ងៃ, ពិធីឧបនិ-ប័ទនិងថ្ងៃមួយនៃពិធីនេះ ត្រូវធ្វើឲ្យត្រឹមត្រូវតាមអគ្និស្តោមៈ (ពិធីសូត្រសរសើរព្រះអគ្និ) ។

រីឯ ថ្ងៃទីពីរជាពិធីធំបំផុត គឺថ្ងៃនោះ គេយកសេះញីទៅបង្ហាញសេះ (អស្វមេធៈ) គេយកសេះនេះទៅទឹមរថចម្បាំងវិចិត្រដោយមាស ហើយគេនាំទៅកាន់ត្រពាំងមួយ គេយកប្រេងទៅលាបសក់និងកន្ទុយសេះ ហើយយកគជ់ ១០១ ទៅបិទភ្ជាប់ ។ ពេលនេះ ជាពិធីសម្លាប់សត្វបូជាធំ មានសត្វផ្សេង ៗ ចំនួន ៦០៩ គេយកទៅប្រជុំហើយចងបង្គោលនៅជុំវិញសេះ (អស្វមេធៈ) ហើយគេសម្លាប់បសុសត្វទាំងនោះខ្លះគេលែងចោលទៅវិញ ទើបគេធ្វើពិធីយជ្ញៈ គឺសម្លាប់សេះ (អស្វមេធៈ) នោះ ដោយការបន្ទប់មិនឲ្យដកដង្ហើមរួច ។ ព្រះជាយាទាំងឡាយត្រូវដើរជុំវិញខ្មោចសេះនោះ ឯព្រះអគ្គជាយា

ត្រូវទៅផ្ទំនៅក្បាលសេះ សំដែងកាការហាក់ដូចជាបង្កាត់កូន ។ ព្រាហ្មណ៍អ្នកបួសនិងស្ត្រីដទៃទៀត និយាយតគ្នាលេងដោយពាក្យឥតខ្លឹមសារកាសកាស តមកមានការសន្ទនាគ្នាដោយប្រស្នា ឬ ពាក្យបណ្តៅរវាងហោត្រនិងអ្នកធ្វើពិធី តមកមានធ្វើបូជាពោះវៀន ។ (Epiploon) ទឹករលាម, ផុំសាច់សេះទំនសត្វឯទៀត , ព្រមទាំងបូជាលោហិតទៀត ។

រីឯ ថ្ងៃទី ៣ មានធ្វើពិធីហៅថា អតិរាត្រៈ បញ្ចប់ដោយពិធី អវភ្ឫថ (Avabhṛtha) គឺការស្នានៈ (ងូតទឹក) មានអ្នកទោសឧក្រិដ្ឋនិងអ្នកនេសាទចូលផង ។ ដើម្បីសម្រេចមានការសម្លាប់គោញីអា ២១ ទៀត ការចែករង្វាន់ទានទៅដល់អ្នកបានរួមធ្វើពិធីអស្វមេធៈទាំង ៣ ថ្ងៃ ហើយបញ្ចប់ដោយការឲ្យដាក់នានអគ្គជាយាទាំង ៤ នាក់ ព្រមទាំងបរិវារដល់ព្រាហ្មណ៍អ្នកបួស ។

x

x x

គ្រួសារ.– ព្រំដែនសកម្មភាពនៃសង្គមឥណ្ឌាពីបុរាណ សម្រាប់ជនថ្នាក់កណ្ដាល មិនតាំងនៅឆ្ងាយពីវិស័យស្រែចំការខ្លួនទេ ៗ ជនម្នាក់ៗ ដែលមានពូជពង្សជាមួយគ្នា តែងតែរស់នៅជាមួយគ្នាតាមច្បាប់ ក្រុមនីមួយៗ សុទ្ធតែជាញាតិសន្តាន ៗ ជន្មន (Janman) គឺបិតាជាមេខ្សែស្រឡាយតំណពូជពង្សពីមួយទៅមួយ ជាប់ទាក់ទងគ្នារឹក ហើយរស់នៅក្នុងគ្រាមជាមួយគ្នា ៗ

ពួកអាយ៌នដែលជាអ្នកលុកលុយ ជាជនពនេចរ មិនមានគ្រាមដូចពួកទ្រាវិឌ ជាអ្នកកំណើតស្រុកទេ តែមានកូនចៅតពូជពង្សកាន់ប្រពៃណីគ្រួសារជាប់តាមនាទីខ្លួន ហើយការពារបុរាណភាពត្រកូលខ្លួនទុករហូតមក ព្រោះជាករណីយកិច្ចសង្គមរបស់ខ្លួនដោយពិសេស ៗ គម្ពីរវេទជាជំនួយជួយរក្សាប្រពៃណីដែលខ្លួនត្រូវបារម្ភខ្លាចសាបសូន្យទៅយ៉ាងខ្លាំងបំផុតៗ រីឯសង្គមទ្រាវិឌ ដែលត្រូវគេលុកលុយផ្សងទៅវិញ មានទី

ស្ថាននៅជាប់នឹងដីខ្លួន មានស្រែចំការតាមជនបទ ហើយមាន តាំងក្រុងថែមទៀតផង ។ ដូច្នេះ ការកិច្ចគ្រួសារ នៃជនខ្មែរ ឋិតថេរនៅបានតាមកាលនៃប្រវត្តិសាស្ត្រ ដូចការបូជា (Cultes) គង់គុបិជាដើម ហើយដឹកនាំឲ្យអាយ៉នការតាមខ្លួនខ្លះផង ។ លក្ខណៈតាមនិងជួននេះហើយ ដែលបញ្ជាក់ការណាយខ្ញុំ ប្រពៃណីនៃជនជាតិខ្មែរ ឲ្យឃើញច្បាស់លាស់ ។ ក្នុង កាលសម័យនោះ ។

គ្រួសារនីមួយៗ នៃជនខ្មែរសព្វថ្ងៃនេះ មិនទៅក្នុង មណ្ឌលនៃពូជពីរ ដែលមានមូលដ្ឋានផ្សេងគ្នា ។ មត្តេយ្យ-តានិងពហុបតិភាព នៅមានឋិតថេរក្នុងវត្តជាគ្រោះបុគ្គល, ដំណែល ឬ អនុស្សាវរីយ៍ ក៏នៅមានឋិតថេរដែរ ។ ឯអាយ៉ន ផ្សេងទៅវិញ មានតែឲ្យស្រឡាយជាប់គ្នាមក ដែលគេហៅថា ជន្ទន គឺដើមកំណើតពូជតាមឪពុក ហើយ ដឹកនាំឲ្យអនុជនកាន់តាមក្រោយគំរូពូជមក ។

គ្រួសារអាយ័ន មានសមាសភាពក្មួយនិងក្មួយជីដូនមួយផង តាមខ្លួននៅដែលគឺ ជន ជំទួន រួមខ្សែស្រឡាយច្រើនបានទៅជាគោត្រមួយ ហើយក៏បានទៅជាកុលសម្ពន្ធមួយមានសភាគ្រាមមួយ ហៅថា បញ្ចូយ័គ ។ ព្រឹត្តិការណ៍ជនអណ្ដាដែលចាស់បរមបុគ្គណានោះ គឺក្រុមសង្គមតូច ឬ ធំដែលមានខ្សែស្រឡាយទាក់ទងគ្នា ដែលហៅថា "គោត្រ" ។ រីឯលក្ខណៈពិតនៃគោត្រនេះ មិនមែនមានតែក្រុមសាច់ញាតិដែលមានឈាមជាមួយគ្នាប៉ុណ្ណោះទេ គឺមានតាមក្រុមខ្លួនដែលប្រតិបត្តិសាសនាជាមួយគ្នាទៀតផង ដែលហៅថាញាតិសន្តាន គឺហៅចំពោះតែអ្នកដែលគោរពបូជាបុព្វបុរសជាមួយគ្នាតែប៉ុណ្ណោះ ។ សេចក្ដីនេះបញ្ជាក់ឲ្យឃើញច្បាស់ថា សង្គមអណ្ដាជាធម្មជាតិសង្គមច្រើនជាងគូនៃញាតិសន្តាន ។ បើប្ដីដែលមិនមានកូនប្រុស ដើម្បីរក្សាការកិច្ច នៃគ្រួសារឲ្យបើកដើរទៅបានទេ, គេត្រូវតែយកប្រពន្ធខ្លួនទៅឲ្យប្រុសដទៃទៀត

ដើម្បីឲ្យបានកូនប្រុសទុកជាមេគ្រួសារតទៅ ។

បិតា ជីតា ឬ បុព្វបុរសជាមេគ្រួសារ ហៅថា "បតិ" ដូចប្រពៃណីខ្មែរយើងថាប្ដី ជាមេគ្រួសារក្នុងផ្ទះនីមួយ ៗ នេះព្រោះតែយើងកាន់តាមទំនៀមវណ្ណា តាំងពីបុរាណរៀងរហូតមក ។ ឯមេក្រុម ដូចខ្មែរយើងហៅថា "មេភូមិ" ហៅថា វិឝ្បតិ (វិឝ ពួក, ក្រុម+បតិ មេ, ម្ចាស់) ។ ឯវិឝ្បតិនេះ ត្រូវជ្រើសតាំងឲ្យទៅជាសេនាបតី ក្នុងកុលសម្ពន្ធខ្លួនទៀតផង ហើយឲ្យឈ្មោះ "រាជ=ស្ដេច" ដើម្បីគ្រប់គ្រងកុលសម្ពន្ធខ្លួនឲ្យមានរបៀបរៀបរយ (សំ. Rājati=) អវេស្ដ: Rāzayeiti ។ អំណាចដែលត្រូវជ្រើសតាំង រាជ នេះ ត្រូវសភានៃកុលសម្ពន្ធជ្រើសតាំង ដូច្នេះ សភានេះ តមក មានន័យច្បាស់ហួសដូចរដ្ឋសភាយើងក្នុងបច្ចុប្បន្នកាលនេះ ។ នេះហើយជាវិជ្ជាបុរាណដើម តមកកើតបានទៅជាស្ថាប័នល្អមួយក្នុងអនាគតឡើង ។

X

X X

ការបូជាក្នុងគ្រួសារ (Cultes familials) .— អគ្គិជា
ជើងក្រានកណ្តាល ជើងក្រានជាឯកភាព ជើងក្រានជាការ-
កិច្ចធំបំផុតនៃគ្រួសារនីមួយ ៗ ប្រពៃណីគោរពអគ្គិនេះ មក
ពីបុរេកាលតមក តាមកាលនៃប្រវត្តិសាស្ត្ររបស់លទ្ធិហិណ្ឌូ
ជាលទ្ធិសាសនានៃអារយ៉ន មុនប្រវត្តិសាស្ត្រ ព្រោះគេបាន
ឃើញមានចារទុកក្នុងគម្ពីរវេទ ៗ

គ្រួសារនីមួយ ៗ ត្រូវតែមានជើងក្រានគឺ អគ្គិ
មួយ, គេទុក អគ្គិ នេះ ជាម្ចាស់នៃគេហដ្ឋានដែលហៅថា
“គហបត្យ” បើជាម្ចាស់នៃគ្រាមហៅថា “វិស្បតិ” ដូច
ជាបិតាដែលជាមេគ្រួសារដូច្នោះដែរ តាមទំនាសម្ពន្ធគួបផ្សំ
នៃគោត្រនោះ ៗ អគ្គិនេះ កាលដើមឡើយ គេដុតបំពក់
ទុកនៅតែក្នុងជ្រុងនៃផ្ទះនោះ ដើម្បីការពារសត្វសាហាវយង់
ឃ្នង ឬក្រុមអ្នកគង្វាលខិនហ៊ុនសត្វពាហនៈ ដែលហៅថា
“គោបៈ” ទៀមានការតាំងនៅដោយប្រពៃតែប៉ុណ្ណោះទេ តែ

តមក អគ្និនេះ មានន័យទៅជាតែពហុរូប គឺមិនមែនផុត
បំពក់ចំពោះតែត្រឹមកិច្ចការជើងក្រានទេ ដោយពិត គឺផុតដើម្បី
បំភ្លឺលោក ដូច្នេះអគ្និនេះ គេទុកជា "ទេពអគ្និ" គឺ "វិទ្យុត=
ផ្លេកបន្ទោរ" ឬ "ពេទិត្យ=ថ្ងៃ" ។ វិទ្យុត=(ផ្លេកបន្ទោរ)
មានកំណែនាចខ្លាំងណាស់ តែជាមិត្រនៃមនុស្សលោក សម្រាប់
បំផ្លាញសត្រូវ ធ្វើឲ្យមានកំដៅឲ្យតត្ថុពាក្យក្នុងលោករស់នៅបាន
តមកទៀតកើតទៅជាតែទិព្វ ហៅថា "ទេវៈ" ដែលកំពុង
តែនេះបំភ្លឺលោកសព្វថ្ងៃនេះ ។ ទេវៈនេះខ្ពង់ខ្ពស់ជាងមនុស្ស
ដូចជាឋានសួគ៌ ខ្ពង់ខ្ពស់ជាងឋានមនុស្សលោកដូច្នោះដែរ តែ
មិនមានអ្វីជាគ្រឿងដែលមនុស្សលោកឲ្យប្រសើរជាជាងជើងក្រាន
ដែលចំអិនអាហារ ឬ ធ្វើពិធីបូជា ពុំនោះជាអធិបតីនៃអំពើគ្រប់
ជំពូក ក្នុងជីវភាពមនុស្សនេះទេ ។ ឯអគ្និនេះ មិនមែនដូចទឹក
ដែលហូរចេញមកពីពពកដូច "ខ្សែទឹក" (Apām nabhāt) ទេ
គឺកើតចេញមកពីការព្យួតឈើពីរទួតពីរ ដែលហៅថា "អរណី"

បើអ្នកណាថែរក្សាភ្លើងនេះទុកដោយប្រយ័ត្នមិនឲ្យរលត់ទៅវិញបាន គឺទៅតែនេះជានិច្ចរហូតទៅ អ្នកនោះគេទុកជាបុគ្គលមានកិត្តិសំណាងប្រសើរណាស់ ។ បណ្ឌិតពុកណាជាជនហិណ្ឌូ ឥរាន ដែលជាអ្នករក្សាភ្លើងដើមគ្រានោះ ហៅថាអថវ័ន ប្រែថា "អ្នកបួសរក្សាភ្លើង" ។

មួយទៀតការរក្សាភ្លើងទុកបន្តវង្សត្រកូល ការរក្សាវិញ្ញាណ-ហិតពីបុព្វបុរសតមកទៀត មិនមែនគ្រាន់តែជានិមិត្តរូបទេ គឺត្រូវពិតប្រាកដមែនទែន ។ ភ្លើងដើមគ្រានេះទុកជា "បុព្វបុរស" គឺជាបិតា ជីតា ឬជីតាទួតលួតណា ដូចជាជនជាតិចិនរក្សា "កុងម៉ា" ឬជនជាតិក្រិករក្សា "ត្រិបិតុរ" (Tripitores) ពុំនោះដូចជាជនជាតិហិណ្ឌូបុរាណរក្សា "សបិណ្ឌបិតរស" (Sapinda Pitares) ដែរ ហើយមានសំណាបកុងគ្រួសារផង ។ ភ្លើងដែលឆេះគគុល ហើយបញ្ចេញអណ្តាតភ្លឺថ្លាៗ ក៏ស្មើទុកជាជីវិតបុព្វបុរសគឺបិតាជីតាជីទួតលួតណា ដែលមានលក្ខណៈ

សក្តិសិទ្ធិរស់រវើកដល់មកសព្វថ្ងៃនេះ ។ ឯគ្រឿងពលីជាអាហារបូជាដល់បុព្វបុរស ដែលស្លាប់ទៅនោះ ព្រាហ្មណ៍ដុតវាក្នុងភ្លើងដែរ ទើបបានដល់ទៅអ្នកដែលស្លាប់ ។

ដោយអាស្រ័យវត្ថុ គឺភ្លើងឆេះគ្រាន់ដែលគេទុកជាខ្សែលោហិតនេះ បានជាពិភពលោកនេះកើតបន្តៗគ្នា ពីមួយទៅមួយស្មើជាដរាបទៅ ហើយភ្លើងនោះក៏ដូចជាតិបានជាអាកាសក្តី, អាកាសក្តីនេះទុកជាបិតា ហៅថា ទ្យុសបិតរ (Dyeus-pitar) ជាគោលជំនឿនៃជនជាតិឥណ្ឌូអារយ៉ន ដូចជាប្រពៃណីក្រិក-ឡាតាំងថា (Zeus pater = Jupiter) ។ ជំនឿទាំងនេះ បង្កើតឲ្យកើតជាលោកវិទ្យា (Cosmologie) និងទេវកថាវិទ្យា (Mythologie) ដែលបណ្តាលឲ្យមានពិធីបូជាគ្រួសារដែលជាកិច្ចនឹងខានធ្វើពុំបានឡើយ ។ ឯការទាក់ទងទៅកាន់ទេវលោក ត្រូវធ្វើទៅតាមភ្លើង យកភ្លើងជាស្ពាន ដូចជាការទាក់ទងទៅកាន់បុព្វបុរសដូច្នោះដែរ ។

បណ្ដាភ្លើងទាំងអស់ ភ្លើងអគ្និនេះ ទុកជាភ្លើងឧត្ដមបំផុត ។ ឯម្ចាស់គ្រួសារ ជាអ្នកធ្វើពិធីយជ្ញៈ ។ កាតព្វកិច្ចខាងគារវ-កិច្ចនេះ មានគ្រោទុកដោយពិសេស ក្នុងក្បួនពិធីបូជាប្រចាំគេហដ្ឋាន ហៅថា គ្ឫហ្យសូត្រ ។ គម្ពីរគ្ឫហ្យសូត្រនេះ ជាគម្ពីរឯក ឬធំបំផុតសម្រាប់គ្រួសារ ។ មានគម្ពីរមួយទៀតហៅថា "ស្រៅតសូត្រ" ជាគម្ពីរនិយាយពីការធ្វើពិធីបូជាតាមការបានស្ដាប់មក ដែលហៅថា (ស្រុតិ çruti) ។ លោកនៅវែ Krouer សរសេរថា ភ្លើងអគ្និទុកជាភ្លើងទីមួយ ដែលម្ចាស់គេហដ្ឋានត្រូវធ្វើពិធី ហើយតមកមានភ្លើង ២ ទៀតទៅជា ៣ សម្រាប់ពិធីសោមៈ ភ្លើងមួយត្រូវដាក់លើអាសនៈទិសខាងកើត ហៅថា "អាហវនីយ" មានកងបួនជ្រុង មួយទៀតមានទ្រង់ទ្រាយជាអឌ្ឍចន្ទ្រ ត្រូវដាក់នៅលើអាសនៈទិសខាងត្បូងពីអាសនៈប្រចាំគេហដ្ឋាន ដែលហៅថា អន្វាហារ្យប-ចនៈ ឬទក្សិណាគ្និ ។ ភ្លើងទាំងពីរនេះ ត្រូវដុតបន្តមកពី

ភ្លើងជើងក្រានដែលជាភ្លើងទីមួយ ៗ ការសុខៈគន្ធិនៃគហបតី នេះ ហៅថា «វេទិកា» (Autel) មានទំហំតូច គឺជាគុកគំនរឧស (សមិធ) ឬ ស្មៅគុគ: មានទ្រង់ទ្រាយបួនជ្រុងទ្រ-វែង ហើយជ្រុងទាំងបួនចុះប៉ូលមកបន្តិច ជាទីសម្រាប់ដាក់គ្រឿងពលីដូច ទឹកដោះ ទឹកដោះខាប់ គ្រាប់ពូជ សាច់ សុរា ៗ នៅលើវេទិកានេះហើយ ដែលទេវតាបំពេញនៅការស្រះបញ្ចូលយកយជ្ញៈ ៗ វេទី ទោះធំក្តី ឬ ទោះតូចក្តី ជាការបូជា-នេ ដែលពិធីបូជានោះ ជាកិច្ចការចាំបាច់បំផុត ហើយមានការញៀកញៀកច្រើនបំផុត ៗ ម្ចាស់ផ្ទះត្រូវបំពេញកាតព្វកិច្ចខាងការកិច្ចនេះ តាំងពីព្រឹក រហូតទៅដល់ល្ងាច ៗ វេលាសន្ធិយាព្រឹក ម្ចាស់ផ្ទះមានកិច្ចត្រូវប្រតិបត្តិច្រើនប្រការ ដូចត្រូវទៅមុជទឹកហូរ (ទឹកស្ទឹង?) ជម្រះធ្មេញ តែងសក់ ហាក់

ផងដង្ហើមខ្យល់ចេញចូល សូត្រគាថាគាយត្រី(១) ជាមន្ត្រ សក្តិសិទ្ធិថា :

ឧមិ ភូរ ភុវៈ ស្វៈ
តត៑ សវិតុរ វរេណ្យម៑
ភគ៌ោ ទេវស្យ ធីមហិ
ធិយោ យោ នៈ ប្រចោទយាត៑ ។

ក្នុងការបំពេញកិច្ចបូជានេះ មានអត្ថបទគម្ពីរវេទផ្សេងៗ ទៀតច្រើនណាស់ ។ គបក ម្ចាស់ផ្ទះត្រូវធ្វើមហាយញ្ញៈ គឺ បូជាទេវតាភូត, បិត្រ, ន្រ ។ ការបូជាអស់ទាំងនេះ ជាការ បំពេញបដិសណ្ឋារកិច្ចចំពោះទេវតា ឯការបូជាព្រហ្មន៍ ត្រូវ

១ ក– ញ្ញាត្តិប្រកបដោយកិត្យានុភាពណា ឧម: ១- តាមនៃលោកទាំង៣ជាន់ ខ្ពស់គឺ ដី អាកាស ឋានសួគ៌; ត-៣ជាទាំង ៣ បាទ នេះ ដកស្រង់ចេញមកពី ឫគ្វេទ (111.62, 10) មានព្រះគ្រាំប៊ីតៈ «ពន្លឺដែលយើងគប្បីប្រាថ្នា ជាភាពនៃទេវតាសាវិត្រ យើងសូមឲ្យបានសប្បាយភាពនោះ ព្រះសវិត្រនោះ ចូរដាស់តឿនចិត្តយើង» ។

ធ្វើដោយការអានគាថាវេទ ជាកិច្ចគោរពចំពោះគ្រូគ ៗ តមក
ទៀត ម្ចាស់ផ្ទះ ត្រូវគោរពទេវរូបប្រចាំផ្ទះ (អាយតនៈ) គឺ
ប្ដីដែលជានិមិត្តរូបនៃទេវតា ដូចរ៉ែ គិរ ខុគាំ គះណាគ ស្ទះ
ជាដើម ៗ ពល់ព្រឹកពល់ល្ងាច ត្រូវធ្វើពិធីអគ្គីហោត្រ គឺការ
បូជាភ្លើងតាំងពីញែបរនះ ៗ ពេលបាយថ្ងៃត្រង់ ត្រូវបោះដុំ
បាយទៅក្នុងភ្លើង ទុកជាការបូជាទេវតាតាំងឡាយ (វៃស្វៈទេវ)
រួចហើយយកដុំបាយតូច ៗ ទៅដាក់នៅខាងក្នុងគេហដ្ឋាន និង
ខាងក្រៅគេហដ្ឋាន ជាកិច្ចបូជាចំពោះទេវតា ភូតបិសាច និង
សត្វតិរច្ឆាន ទើបបានតួកប្រុស ៗ ចាប់បរិភោគអាហារ ក្នុងវេ
តែខ្លួន ស្ត្រី ៗ បំរើ បំរើរួចហើយ ទើបបរិភោគខ្លួនឯង
ជាខាងក្រោយ ៗ វេលាសន្ធ្យាល្ងាច ពេលព្រះអាទិត្យ
អស្តង្គត ត្រូវប្រតិបត្តិជាថ្មីទៀត ៗ

ទិសរួមនាការជីវិតនៃជនណាម្នាក់ ១ .- ជនណា
ម្នាក់ ៗ មានកិច្ចត្រូវធ្វើពីដើមរហូត ៤០ ឆ្នាំ បេះបា សំគាល់

ប្រែថា "ធ្វើឲ្យសក្តិសិទ្ធិ ឬស័ក្តិ" គឺធ្វើឲ្យបរិសុទ្ធ ឲ្យបានកូន បើប្រុសឲ្យបានជា គ្រហបតិ បើស្រីឲ្យមានប្ដី ដោយសង្ខេប ពិធីនេះ មាន ១២ ប្រការ គឺ

១- ពិធី ក្ដ.បញ្ចោះព្រំគភ៌ ហៅថា "គភ៌លម្ភនៈ ឬ គភ៌ាធានៈ" ពិធីនេះ ត្រូវធ្វើក្រោយមង្គលការ ៤ ថ្ងៃ ជាពិធីការតាមរបៀបមង្គល ហើយឲ្យបានកូនប្រុស ធ្វើដូចគ្នានឹងពិធីឈ្នរលោកខ្មែរយើង ៗ ក្នុងពិធីនេះ ត្រូវប្ដីយកស្បូវក៏ទៅឲ្យបំពាល់ភរិយា ...ពីផ្ចិតចេញមក រួចហើយសូត្របន្ទស់ថា "សូមព្រះវិស្ណុរៀបចំគភ៌ឲ្យ" "សូមព្រះបរិត្តលោក កជារូបកូនស្អី" "សូមព្រះបជាបតិជាអ្នកបញ្ចោះព្រំឲ្យ" "សូមព្រះបរិត្តលោកញ្ញាំងកូនឲ្យកើតក្នុងគភ៌" ។ ពិធីនេះនៅមានក្រៅពីបបកដល់សព្វថ្ងៃនេះ តែច្រើនតែក្នុងពួកហិណ្ឌូដែលជាគ្រហបតិបន្ទ ។

ជនហិណ្ឌូច្រើនចង់ស្រឡាញ់កូនប្រុស បើមានកូនស្រី

គេទុកជាជាអភ័ព្វ គម្ពីរនិយាយថា "មានតែកូនប្រុសទេ ដែលអាចរៀបចំពិធីបុណ្យសពឪពុក ហើយអាចនាំឲ្យទៅកើតឋានសួគ៌បាន" ។ កូនប្រុសហៅថា "បុត្រ" មានន័យ "អ្នកជួយដោះទុក្ខពុកម៉ែមិនឲ្យធ្លាក់ទៅនរក" ។

២– ពិធីបន្ទាប់សុំឲ្យបានកូនប្រុសហៅថា "បុំសវន" ។ ពិធីនេះ ត្រូវធ្វើក្នុងពេលដែលមានគភ៌ ៣ ខែហើយ ត្រូវបង់ ៣ ដងក្នុងមួយថ្ងៃ ដើម្បីឲ្យបានកូនប្រុស ។ ក្នុងពិធី គេយកមេត្រាប្រោះព្រំចុះច្រមុះខាងស្ដាំនៃភរិយាដោយបែកបិត្រោគ ឲ្យផឹកទឹកដោះ ហើយសួរថាផឹកអ្វី ? ភរិយាឆ្លើយថា "បង្កើតកូនប្រុស" ពិធីនេះហៅថា "អនវលោភន" ក៏បាន ។

៣– ពិធីបន្ទាប់ញែកសក់ ហៅថា "សីមន្តោនយន:" ។ ពិធីនេះ ត្រូវធ្វើដោយតាក់បន្ទ្រាប់ប្រេងក្រអូបទៅលើក្បាលប្រពន្ធ ហើយញែកសក់ពីប្រជុំចិញ្ចើមមកឲ្យនៅត្រង់កណ្ដាលក្បាលបែបដូចជាយកផ្កាដោយដៃខ្លួនឯង មួយទៀតមានន័យថា សក់នៅ

ទុកជាស្បៀវគុត: ៣ សរសៃ ហើយយកសក់ដែលទុកជាស្បៀវ គុត:ទៅដាក់ត្រង់ប្រម៉ុំចិញ្ចើម ៣ ដង ម្ដង ៗ ត្រូវសូត្រគាថា វេទថា កុរិ កុរិ និង ស្វរិ ព្រមទាំងវិបនៈថា “ឱម” ជាពាក្យនមស្ការក្រឹម្ហកំទេវតាផង ៗ តាមពិធីនេះ គេជឿថា ដេញគ្រោះចង្រៃចេញ ហើយបញ្ចូលតពកុំនក់ប្រពន្ធដើម្បី ការពារអន្តរាយដល់កូនដែលមិនទាន់កើត ៗ

(៤) ពិធីមង្គលចាប់កំណើត ហៅថា “ជាតកម៌ន” ៗ ពិធីនេះ ត្រូវធ្វើក្រោយពេលដែលកូនកើតហើយ មុនកាត់ទងសុក ត្រូវឪពុកយកស្លាបព្រាមាស ដែលដាក់ពេញដោយទឹកឃ្មុំ និងទឹកដោះគោខាប់ ទៅដាក់និងបបូរមាត់កូន ហើយសូត្រមន្តស្រទន់តាមគម្ពីរវេទថា “ឱព្រះមានអាយុវែង ! សូមឲ្យកូនខ្ញុំនេះមានអាយុ ១០០ ឆ្នាំនៅនាលោកនេះ ដោយការគុណនៃទេវតា” ក្រោយពីការដាក់បបូរមាត់ ត្រូវដាក់ត្រចៀកកូនទៀត ហើយសូត្រថា “សូមព្រះសាវិត្រី សូមព្រះ

សរសើរគឺ សូមព្រះអគ្គិន ប្រសិទ្ធិឲ្យកូនមានប្រាជ្ញាជ្រៅឈ្លាស
គទៅវៃបំផុត រឹតសក់កូន ហើយសូត្រថា "ឲ្យឯងមាំមួនដូច
ថ្ម មុតដូចប៉ូថៅ បរិសុទ្ធដូចមាស ឲ្យឯងរស់នៅ ១០០ ឆ្នាំ
សូមព្រះឥន្ទ្រប្រគល់ឲ្យនូវកំណាប់ទ្រព្យដ៏ប្រសើរដល់ឯង" ៗ

(៤-) ពិធីបន្តល់ឲ្យឈ្មោះហៅថា "នាមករណ" ៗ
ពិធីនេះ មានចូលទៅពេញប្រទេសឥណ្ឌា គេធ្វើពេលក្រោយ
កូនកើត ១០ ថ្ងៃ ឬ ១២ ថ្ងៃ ៗ គ្រួសារដែលមានកូនកើត
បាន ១០ ថ្ងៃ គេចាត់ទុកជាគ្រួសារមិនស្អាត ៗ មុនធ្វើពិធីឲ្យ
ឈ្មោះ ត្រូវធ្វើពិធីលាងបាបមួយមុនសិនគឺ "ម្តាយត្រូវមុជ
ទឹកឲ្យស្អាត ជញ្ជាំងបន្ទប់ត្រូវលាបអាចម៍គោ ឯបន្ទប់មុជទឹក
ក៏ត្រូវសំអាតឲ្យមត់ចត់ណាស់ដែរ ត្រូវប្តូរជាមានពណ៌ក្រហម
លាបម្សៅ ហើយដុតចង្កៀងឲ្យភ្លឺ ត្រូវមានគ្រឿងបូជាផ្សេង
ទៀតដូចជា ប្រាក់ អាវទ្រនាប់ និង សំពត់ លុះបំពេញកិច្ច
ការទាំងនេះបរិបូណ៌ហើយ ទើបគប់ថា គ្រួសារនោះបានធ្វើ

ឲ្យបរិសុទ្ធហើយ ។

ជនហិណ្ឌូយកចិត្តទុកដាក់ក្នុងការឲ្យនាមនេះណាស់ ។

គ្រូហោរគន់គូរមើលផកាកសី ជ្រើសនាមឲ្យបាន ៣ ឬ ៤ ហើយឲ្យឪពុកជាអ្នករើសយកឈ្មោះណាមួយ ។ អក- ...ហិណ្ឌូមានហោរជំនាញគន់គូរយូរទៃណាស់ ឯពិធីឲ្យនាម ...បួនយប់ទៅថ្ងៃក្រោយទៀត ។ បើនាមតាមជាតផកា

...នាមដែលគេឲ្យក្នុងពេលកើត ១០ ថ្ងៃនោះទេ កូន ...យកនាមទៅតាមជាតផកាវិញ ។ នាមត្រូវរើសយកពាក្យ ...ាវីផល់នកុត្តបុក្យ ។ ឯនាមពិតមែនរបស់កូននោះ មិនមែននាមដែលគេឲ្យក្នុងថ្ងៃធ្វើពិធីនាមករណៈ ឬ នាមតាមជាតផកាទេ គឺនាមសម្ងាត់ដែលគ្រូបាធ្យាយខ្សឹបឲ្យ នាមនេះទើបជានាមមែនទែន ។ បើជនណាមួយតាបដឹងនាមនេះបាន គេជឿថាមានអំណាចទៅលើអ្នកនោះណាស់ ។

កូនប្រុសត្រូវឲ្យនាមតាមឈ្មោះទេវតាប្រុស ដូចជាក្ឫស្ណា,

កម, គោបាល, គណេក, សង្កែ ។ល។ ឬនាមទៅតា ប្រុសពីររួមគ្នា ហរិ-ហរ គិរ-កម គោបាល-កុម្ភ លក្ស្មី-នារាយណ៍ ឬតាំងនោះឱ្យឈ្មោះថា ទាស ខ្ញុំទេវតា ដូច ហរិ-ទាសី កាលិ-ទាសី គោបាល-ទាសី ទុគ៌ា-ទាសី ឬ នាមក្ស័យហាការយុទ្ធ: អជ៌ុន ភីម ហនុមាណ ។ល។

កូនស្រីត្រូវឱ្យនាមៈទៅតាមនាមទេវតាស្រី: សរស្វតី បរ៌តី លក្ស្មី ឬមាមក្តា ស៊ីតា ពេជ្រ ឬតាំងនោះ គុណសម្បត្តិ ដូច កមល ឬ កមលបី, កុសុម, មុតិ, (តុជ) វិមល, សុន្ទរី, ប្រេម, មោភិនី (ល្អ) សេត្តិ ឥន្ទ្រា យមុនា គោទាវរី កវេរី ។ល។

៦– ពិធីមង្គលនាំចេញទៅក្រៅហៅថា “និក្រមណា” ។ ពិធីនេះ មិនធំដុំប៉ុន្មានទេ ត្រូវធ្វើក្នុងខែទី ៤ ក្រោយខែកំណើត ដែលកូនកើត គឺត្រូវម្ដាយបីកូននាំចេញទៅខាងក្រៅ ទៅ នៅកណ្ដាលវាល តាមក្រោយប្ដី ត្រូវបង្ហាញកូនទៅព្រះ

គាថាក្យហើយសូត្រថា "វៃក្ខកជាពន្លឺ ជាមង្គលដល់ទេពតា ដែលរះឡើងពីទិសខាងកើត សូមឲ្យកូនយើងរស់នៅបានអាយុ ១០០ ឆ្នាំ" យើងសូមពរថា ៈ ស្តាប់ និយាយ មានសេរី ដោយអំណាចទេពតាអស់កាល ១០០ ឆ្នាំ ។ តពីនេះទៅទៀត មាតាបិតាយកកូនទៅកាន់ទេវាល័យក្នុងភូមិ ហើយបន់សូមឲ្យកូនបានល្អ ។

៧- ពិធីមង្គលឲ្យអាហារហៅថា "អន្នប្រគន" ។ ពិធីនេះ ត្រូវធ្វើក្រោយពេលដែលកូនកើតហើយបាន ៦ ខែ ត្រូវប្រជុំញាតិមិត្តឲ្យមកជួបជុំគ្នា ហើយឲ្យកូនបរិភោគអាហាររឹងជាបឋម ។ ព្រាហ្មណ៍សូត្រគាថាវេទឲ្យពរ តពីកូនស៊ីមក ត្រូវតៀវបរិភោគអាហារ ។

៨- ពិធីមង្គលកោរសក់ហៅថា "កេសូវ" ។ ពិធីនេះ សំខាន់ណាស់ដែរ ។ ជនហិណ្ឌូយកចិត្តទុកដាក់ក្នុងពិធីនេះណាស់តាមលទ្ធិសាសនាដោយប្រកាន់ជឿថា "សក្តិ-

សិទ្ធិកូនកាលណាខ្លួនមិនចិត្តឲ្យស្អាត" ដូចប្រពៃណីកោរសក់ព្រៃ ឬការកោរសក់ខ្មែរយើងដែរ ៗ ពិធីកោរសក់ខ្មែរយើងក៏ជាមង្គលមួយធំណាស់ដែរ ៗ

៩– ពិធីមង្គលកាត់សក់ហៅថា "កេតាគ្គ" ។ ពិធីតាំងពីដើមគេកោរសក់និងកាត់សក់នេះ មិនប្លែកគ្នាប៉ុន្មានទេ តែពួកព្រាហ្មណ៍ពេញចិត្តនឹងធ្វើណាស់ ៗ កាលបើកូនអាយុបាន ៣ ឆ្នាំហើយ មាតាបិតាតែងធ្វើពិធីនេះឲ្យកូន ឬជួនកាលកូនដល់អាយុ ៧ ឬ ៨ ឆ្នាំ ទើបធ្វើក៏មានដែរ ៗ គម្ពីរកេត្វ-លាយនៈ និយាយថា ក្នុងពិធីនេះ ឪពុកត្រូវយកកូនទៅដាក់លើភ្លៅម្ដាយ ដែលអង្គុយនៅខាងលិចភ្លើងហោមអគ្គិ ឪពុកត្រូវឈរខាងត្បូងម្ដាយ កាន់ស្មៅកុស: ២១ ដើម ហើយប្រោះព្រំក្បាលកូន ដោយទឹកក្ដៅលាយទឹកដោះថ្លាញ់ និងទឹកដោះគោ ៣ ដង ហើយយកស្មៅកុស: ទៅញាត់ខាងស្ដាំសក់កូន ៧ ដង សូត្រថា "ឱកុស: រក្សាអើយ ! សូមរក្សាកូននេះ" រួច

កាត់សក់បន្តិចហុចទៅម្ដាយ ព្រមទាំងសូត្រគាថាផង ទុកប៊ូ-ឌា (កំពោយ) មួយ នៅលើក្បាលកូន ឬ តាមប្រពៃណីខ្លះត្រូវទុកប៊ូឌា ៣-៤-៥ សរសៃ ។

១១-ពិធីមង្គលនាំកូនឲ្យទៅរៀនហៅថា "ឧបនយនៈ" ។

ពិធីនេះ ជាពិធីសំខាន់បំផុតមួយ គេហៅពិធីនេះថាជា "ពិធីបញ្ចូលខ្សែស្រឡាយ" គឺបាន ព្រោះពិធីនេះត្រូវធ្វើដើម្បីឲ្យកូនបានជាប់ខ្សែស្រឡាយជាព្រាហ្មណ៍ ។ ពួកព្រាហ្មណ៍ខ្លះ មិនឲ្យកូនខ្លួន ដែលមិនទាន់បានធ្វើមង្គលឧបនយននេះចូលទៅរួមបរិភោគអាហារជាមួយទេ បើកូនណោះមិនទាន់បានប្រសិទ្ធិជាជាព្រាហ្មណ៍នៅឡើយទេ ។ ដូច្នេះ មាតាបិតាត្រូវនាំកូនប្រុស ឲ្យទៅរៀនគម្ពីរវេទខ្លះ ដើម្បីឲ្យកូនបាននាមថាជាទ្វិជៈ= ព្រាហ្មណ៍ ។ ពិធីនេះត្រូវធ្វើក្នុងពេលដែលកូនមានអាយុឋិតនៅចន្លោះឆ្នាំទី ៧ និងឆ្នាំទី ១០ បើទុកជាមិនហុចឲ្យទេ ត្រូវធ្វើដល់នៅកូនអាយុបាន ១៦ ឆ្នាំក៏បាន ត្រូវ

ហៅញាតិមិត្រមកជួបជុំ ត្រូវមើលឫក្សពារឲ្យបានត្រឹមត្រូវល្អ មុនសិន មុនពិធី ត្រូវកោរសក់កូន ហើយស្រោះព្រំដោយគ្រឿងក្រអូប ។ ព្រាហ្មណ៍អ្នកធ្វើពិធី ត្រូវនាំកូននោះទៅគោរពទេពតាប្រចាំផ្ទះ ហើយឲ្យកូនក្រាបសំពះមាតាបិតានិងភ្ញៀវតមកឲ្យកូនអង្គុយលើកៅអីឈើ ឪពុកអង្គុយទល់មុខ ហើយព្រាហ្មណ៍អ្នកធ្វើពិធីសូត្រគាថា រួចហើយកូនក្រាបសំពះឪពុកម្តាយទៀត គោរពដោយស្ទាបជើងឪពុកដោយដៃ ឪពុកឲ្យពរកូននិងភ្ញៀវហើយ ព្រាចគ្រាប់ពូជធ្វះទៅលើកូន ដើម្បីឲ្យកូនមានជោគ ។ ពេលនេះ ត្រូវដុតភ្លើងដោយឧសស័ក្តិសិទ្ធិដែលលាបដោយខ្លាញ់ទឹកដោះគោ ។ ខ្សែចង ត្រូវយកអម្បោះ ៣ សរសៃមកវេញជាមួយគ្នា ខ្សែ ៣ សរសៃនេះជាត្រីទេព ពណ៌ស ជាពណ៌បរិសុទ្ធ ។ ខ្សែនេះ ត្រូវព្រាហ្មណ៍ប្រសិទ្ធីមុននឹងយកទៅចងកូន កំពុងចងត្រូវសូត្រគាថាវេទ ចងខ្សែហើយកូនសូត្រគាថាតាមគ្រូ ។ ភ្ញៀវត្រូវ

ជាយចេញពីបន្ទប់ឲ្យអស់ ទើបព្រាហ្មណ៍ ប្ដូរពុកសូត្រគាថា
គាយត្រី ជុំបញ្ចូលនូវគ្រឿងក្នុងទាំងពីរោះផង ព្រោះពិធីនេះ
មិនត្រូវសូត្រនៅមុខកៀវទេ ។ លុះសូត្រគាថាគាយត្រីនេះ
រួចហើយ កៀវទាំងឡាយចូលមកអង្គុយតាមកន្លែងដើមវិញ ។

ពីបុរាណ កាលធ្វើពិធីនេះរួចហើយ មាតាបិតាត្រូវយក
កូនទៅប្រគល់ឲ្យព្រាហ្មណ៍ជាគ្រូបង្រៀន ហេតុនេះបានជា
កើតពាក្យថា "ឧបនយន" នេះឡើង ។ ឯពាក្យថា ឧបន-
យន នេះ ប្រែថា "កិរិយានាំកូនទៅប្រគល់ឲ្យគ្រូបង្រៀន"
ដូចជុំនៀមខ្មែរយើង នាំកូនទៅប្រគេនលោកឯវត្ត ។ ឯខ្សែ
បំណាន់នេះ ជាគ្រឿងសំគាល់ថាជាទ្វិជៈ= ព្រាហ្មណ៍ ពេញ
លក្ខណៈ មិនតែប៉ុណ្ណោះទេ ជានិមិត្តរូបនៃគំណតួជព្រមទាំង
ជឿថា មានអំណាចខាងសាសនាគឺនៃគន់ថែមទៀតផង ទើ
នមស្ការទេពតា ជនហិណ្ឌូត្រូវពាក់ខ្សែនេះឆៀងស្មា គឺលើ
ស្មាឆ្វេង ជាយខ្សែធ្លាក់ឲ្យនៅខាងក្រោមស្មាស្ដាំ បែបនេះហៅ

ថា "ឧបវីតិ" បើខមស្ការបុត្របុរសត្រូវពាក់ខ្សែនេះលើស្មា ស្តាំ ដោយទាញមកឲ្យនៅខាងក្រោមស្មាឆ្វេង បែបនេះហៅ ថា "ប្រចិនវីតិ" បើខមស្ការព្រះអរហន្ត ត្រូវពាក់នៅកណ្ដឹ បែបនេះហៅថា "និវីតិ" ។ ខ្សែសក្តិសិទ្ធិនេះ មិនត្រូវឲ្យ ទៅ[illegible]ពាក់ទេ បើដាច់ត្រូវប្រសិទ្ធិខ្សែពាក់មួយទៀត ។ ព្រាហ្មណ៍ខ្លះ ត្រូវផ្លាស់ខ្សែនេះមួយឆ្នាំម្តង ។ រីឯខ្សែនេះ [illegible]ពុះដៃដែរ ក្នុងពេលរៀបមង្គលការកូនប្រុ សទបដៃ ក្នុងពេលបានជួបញាតិសន្តាន ដែលបែកគ្នាយូរ ហើយជាគ្រឿងសំគាល់ថាមានខ្សែស្រឡាយជាមួយគ្នា ។

១១- ពិធីបង្គលវិលមកផ្ទះវិញ ហៅថា "សមវត៌ន" ។ ពិធីនេះ កាលដើមសំខាន់ណាស់ដែរ គឺកាលដែលកូនបាន រៀនចេះចប់ហើយ ត្រូវត្រឡប់មកកាន់ផ្ទះវិញ ក្នុងពេលដែល កូនមកដល់ផ្ទះ មាតាបិតាញាតិសន្តានត្រូវមកជួបជុំគ្នា រង់ចាំ ទទួលដោយសេចក្តីត្រេកអរក្រៃលែង ព្រោះបាត់មុខកូនមក

អស់កាលយូរឆ្នាំហើយ ។ សព្វថ្ងៃនេះ ពិធីនេះមិនមានទេ ព្រោះគេត្រូវធ្វើបន្ទាប់ពីមង្គលឧបនយនវិញ ព្រាហ្មណ៍អ្នកធ្វើពិធីសូត្រគាថាវេទថា "ឥឡូវនេះ ឯងជាព្រហ្មចារី ឥឡូវនេះ ឯងជា គ្ឫហបតិ" តែប៉ុណ្ណោះ ក៏ចប់ពិធីឧបនយននិងសមាវត៌ន នេះទៅ ។

១៤- ពិធីមង្គលការ ហៅថា "វិវាហ" ។ ពិធីនេះ សំខាន់បំផុតជាងពិធីឯទៀតទាំងអស់ ត្រូវធ្វើក្នុងពេលដែលធី-តាចូលក្នុងតរុណវ័យ ដល់ធីតានេះមានរដូវហើយ មាតាបិតាត្រូវប្រាប់ដល់សង្គមទាំងមូលថា ធីតាខ្លួនល្មមរៀបចំការបានហើយ តែគេទុកស្ត្រីភាគក្នុងពេលមានរដូវនេះថាជាស្ត្រីមិនបរិសុទ្ធ ។ ស្ត្រីព្រាហ្មណ៍ក្នុងពេលដែលខ្លួនមិនទាន់បានធ្វើឲ្យបរិសុទ្ធ មិនត្រូវឲ្យនៅលាយឡំក្នុងសង្គមបរិសុទ្ធទេ មិនត្រូវឲ្យចូលទៅក្នុងផ្ទះបាយចំអិនអាហារ ឬពាល់មនុស្សបរិសុទ្ធទេ ត្រូវឲ្យនៅតែម្នាក់ឯងដោយឡែក- ស៊ីតែម្នាក់ឯង ។

ការធ្វើពិពាហមង្គលជាការៈមាតាបិតា សាមីខ្លួនទាំងពីរមិនត្រូវឲ្យជួបគ្នាទេ ហើយលែងតែជួបដោយមិនដឹងខ្លួន ព្រោះគេទុកថាជាការមិនបរិសុទ្ធ ។ សព្វថ្ងៃនេះ វិវាហៈ ជារឿងដែលជនហិណ្ឌូនិយមខ្លួនទៅ គេរៀបចំធ្វើធំណាស់នៅក្នុងវិស្សមាគារនៃព្រាហ្មណ៍ ដំរៃក្រៃលែងធំ មិនមានពិធីណាប្រសើរជាងទេ មានក្បួនហែសម្បើមអស្ចារ្យ ។

តាមគម្ពីរមនុ, ស្ត្រីដែលល្អគួររៀបមង្គលការបាន គឺស្ត្រីមិនពិការកាយ មានឈ្មោះគួរសេពគប់ មានដំណើរល្អាយល្អងដូចដំរី រោមខ្លួនមួសក់ឲ្យមានចំនួនតិច ធ្មេញល្អិតរឹមពីរមាត់ល្អ ។ ស្ត្រីត្រូវមានសក់ក្រហមព្រៀង ១ មានអវយវៈ មិនសមរម្យ ១ ស្ងាំហ៊ាឈឺច្រើន និយាយច្រើនឬក្អកក្រហម ព្រំនោះឥតមានរោម ឬក៏មានរោមច្រើនពេក ទាំងអស់នេះត្រូវវៀរចេញ ។ រដូវរៀបមង្គលការបាន គឺខែមាឃផល្គុណវិសាខ ត្រូវឲ្យហោរាគេទស្សមើលឫក្សពេលាដូចខ្មែរយើងដែរ ។

ពិធីមង្គលការផ្សេងៗគ្នាខ្លះតាមជនបទ ។ តែគោលសំខាន់នោះ
ដូចគ្នាគឺ ត្រូវយកព្រះអគ្គិជាសាក្សី ព្រោះអគ្គិជាទេពតាសក្តិសិទ្ធិ
ពិតរបស់ជនណា ត្រូវយកព្រះអគ្គិទៅដុតនៅកណ្តាលរោង
ដែលរៀបមង្គល ត្រូវយកខ្លាញ់ទឹកដោះដុតជាចង្កៀងកុំឲ្យ
រលត់ សព្វថ្ងៃនេះ គេយកបន្ទៀងប្រេងទៅដុតជំនួសវិញ កូន
ស្រីប្រុសត្រូវធ្វើយញ្ញនៅក្បែរភ្លើង ត្រូវតែគិតខ្លួនទាំងពីរនាក់ឲ្យបាន
ល្អ ខ្លួនស្រីត្រូវយកសំពត់ប៉ុន្មាន ហើយព្រាហ្មណ៍អ្នកធ្វើពិធី
គោរពព្រះអគ្គិ ជាទេពតាងចាន់ឧបសគ្គ ដើម្បីការពារឲ្យ
មានមង្គល គេយកសំពត់មួយទៅចងភ្ជាប់ជាយសំពត់កូនស្រីប្រុស-
សូត្រគាថាវេទ កំពុងសូត្រ ហាប់ដៃកូនស្រីប្រុសទាំងពីរទៅ
ដាក់លើសំពត់ពិធីនេះ សូត្រគាថាវេទនេះផ្សេងទៀត ព្រាហ្មណ៍
ម្នាក់ទៀតជាអ្នកជួយ យកខ្សែទៅចងកណ្តាលកូនស្រីប្រុសទៀត
ហើយបង្គាប់ឲ្យកូនស្រីប្រុសយកបាយ ដូង ព្រោះទៅគន់ដេង
ក្រាបអគ្គិ ៗ របៀបមង្គលការនេះរញ៉េរញ៉ៃណាស់ មាន

ការស្រោះព្រំទឹក បាចម្សៅក្រហម ដើរ ៧ជំហាន ហៅថា "សប្តបទិ" គឺកូនស្រីប្រុសត្រូវដើរជុំវិញភ្លើងគ្រានអគ្គិ ៧ ជុំ តាមបន្ទាប់ព្រាហ្មណ៍ កូនប្រុសដើរមុខ កូនស្រីដើរតាមក្រោយ ។ តាមគម្ពីរនិយាយថា "ជំហានទីមួយ ទុកជាអាហារ ជំហានទីពីរ ទុកជាកម្លាំង ជំហានទីបី ទុកជាសេចក្តីសុខ ជំហានទីបួន ទុកជាសេចក្តីចំរើន ជំហានទីប្រាំ ទុកជាកូនចៅ ជំហានទីប្រាំមួយ ទុកជារដូវ ជំហានទីប្រាំពីរ ទុកជាមិត្រសម្លាញ់" ឯកូនប្រុសត្រូវពោលទៅកាន់កូនស្រីថា "សូមសប្បុរសដល់ខ្ញុំ សូមឲ្យមានកូនច្រើន សូមឲ្យមានអាយុវែងដល់ចាស់ជរា" ។

តាមគម្ពីរមនុ (III, 21) ការរៀបចំកូនប្រុសស្រីឲ្យជាប្តី-ភរិយានេះ ហៅថា "វិវាហ" ន័យដើម "ការពង្រត់យក ឬការចាប់យកដោយកម្លាំង" ពោលដោយសង្ខេបមាន ៨ ប្រការ ។ វិវាហ ៤ ប្រការខាងដើម សំដែងឲ្យឃើញថាជា

ទំនៀមទម្លាប់បុរាណនៃវណ្ណៈអ្នកបួស ជាពិធីការដែលប្រពន្ធស្លាប់ទៅហើយបានទៅកើតឋានសួគ៌ ឯប្ដីត្រូវបានទ្រព្យខាងស្ត្រីហៅថា ស្ត្រីធនៈ ជាមត៌កគឺ៖

១- ព្រហ្មវិវាហ ការរៀបការដោយកូនស្រីពេញចិត្តធ្វើជាភរិយា;

២- ទេវវិវាហ ការរៀបការដោយស្វាមីជាអ្នកបួសយជ្ញ: ហៅថា ឫត្វិជ;

៣- អាសីវិវាហ ការរៀបដោយបិតានៃកូនស្រី បានទទួលគោមួយនឹមដោយសន្ធក;

៤ ប្រាជាបត្យវិវាហ ការរៀបការដោយការស្នើមកពីខាងកូនប្រុស;

៥- អាសុរវិវាហ សម្រាប់វណ្ណៈ វៃស្យ និងសូទ្រ:;

៦- គន្ធវិវាហ ការរៀបការដោយមាតាបិតាទាំងសងខាងពេញចិត្ត;

៧- រាក្សសវិវាហ ការរៀបការដោយពួកក្សត្រិចាប់ពង្រត់ ដូចអ្នកចម្បាំងជាដើម បែបនេះ និងហៅថា ក្សត្រវិវាហៈក៏បាន (ការរៀបការ ៣ ប្រការ គឺទី៥, ទី ៦, ទី ៧ នេះទុកជាការថោកទាប);

៨- បៃសាចវិវាហ ការរៀបការបែបបិសាច គឺចង់បំផ្លាញដោយស្រវឹងស្រាជាដើម បែបទី ៨ នេះ ទាបថោកបំផុត ។

រៀបការប្ដីប្រពន្ធ មានប្រពៃណីផ្សេង ៗ ច្រើនណាស់ ភរិយា អាចមានប្ដីច្រើនក៏បាន តាមទំនៀមបុរាណនៅប្រទេសឥណ្ឌា ហៅថា ពហុបតិកភាព (Polyendrie) ដូចនាងទ្រោបតីក្នុងរឿងមហាភារត មានស្វាមីប្រាំនាក់គឺបងប្អូនបាណ្ឌវទាំង ៥ ។ ការនេះ បំពានខុសនឹងច្បាប់សាសនាព្រាហ្មណ៍ដែលហាមប្រាមមិនឲ្យយកញាតិសន្តានសាច់ញាតិ ជាប្ដីប្រពន្ធនេះ ។ ឯប្ដីក៏អាចមានប្រពន្ធច្រើនបានដែរ ហៅថា ពហុភរិយាភាព (Polygamie) តែប្រទេសឥណ្ឌាជាប្រទេសក្រីក្រ ការ

យកប្រពន្ធច្រើនជាការធ្ងន់ណាស់ ប្ដីមានឋានៈក្រីក្រមិនអាច
នឹងទ្រការនេះបានទេ មានតែជនដែលមានឋានៈខ្ពង់ខ្ពស់ទេ
ទើបអាចមានប្រាសាទសម្រាប់ដាក់ស្រីជាភរិយាច្រើនបាន ។
ក្នុងយុគសម័យនេះស្ត្រីភាពមានសិទ្ធិស្រាល់ជ្រើសប្ដីបាន ហៅថា
ស្វយម្វរៈ តែសព្វថ្ងៃ ទំនៀមនេះមិនមាន ។ ក្នុងសម័យពុទ្ធ
នៃលោកគោតម អនុញ្ញាតឲ្យរៀបចំការជាមួយស្ត្រី ដែលមិន
ទាន់គ្រប់ការបាន គឺរៀបការតាំងតែពីកូនប្រុសស្រីនៅពីកុមារ-
ភាព ស្ត្រីអាយុ ១១ ឬ ១៤ ឆ្នាំហើយឲ្យទៅនៅផ្ទះខាងប្ដី ហេតុ
ដូច្នេះឯងហើយបានជា មានស្ត្រីមេម៉ាយច្រើនពិតនៅក្នុងវ័យ
ក្មេង ៗ ស្ត្រីមេម៉ាយដែលមិនមានកូន រៀបការម្ដងទៀត
បាន តែមតិមហាជនចូលចិត្តយកស្ត្រី ដែលតាំងចិត្តនៅជា
មេម៉ាយរហូតមកធ្វើជាប្រពន្ធ បើទុកជាប្ដីស្លាប់ពេល ៣ ឬ
៤ ឆ្នាំ ដោយកើតអុតឬកើតរបេងក៏ដោយ ៗ មួយទៀត
មតិមហាជន តែងដឹកនាំឲ្យស្ត្រីលោតទៅក្នុងភ្លើងប្ដីស្លាប់ជា

មួយប្តី ៗ ក្នុងគម្ពីរ អថវ៌វេទ ( 18, 3, 1 ) មានព្រា·ទុកនូវទំនៀមចូលស្លាប់ជាមួយប្តីនេះ តែតាមយតិរបស់យើងគ្រប់គ្នាឃើញថា ទំនៀមនេះមិនប្រពៃសោះសម្រាប់មនុស្សទូទៅ ព្រោះជំនឿថាលោកស្លាប់ទៅជាមួយប្តី ហើយបានទៅកើតក្នុងឋានសួគ៌ មិនមែនជាសច្ចធម៌ទេ ៗ មួយវិញទៀតស្ត្រីដែលប្តីស្លាប់ចោលទៅហើយ មិនមានគេណាយកចិត្តខិងត្រូវធ្វើតាមលទ្ធិសាសនាឡើយ បើជាស្លាប់ត្រូវស្លាប់ទៅជាមួយប្តី ទើបបានទៅកើតក្នុងឋានសួគ៌ ៗ គម្ពីរមនុនិយាយថា "ន ស្ត្រី ស្វាតន្ត្រ្យម៑ ប្រែថា ស្ត្រីទាំងអស់ មិនបានសិទ្ធិតាមទំនើងខ្លួនឯងទេ" ៗ តាមច្បាប់ ប្រុសមិនត្រូវយកភរិយាដែលជាញាតិសោះ, ខ្មែរយើងក៏កាន់តាមទំនៀមនេះដែរ បើទុកជាត្រូវរៀបការជាមួយវណ្ណៈខ្លួន ក៏ត្រូវហាមឃាត់មិនឲ្យរៀបការជាមួយស្ត្រីសបិណ្ឌ គឺស្ត្រីដែលមានបិតបូជនប្រុសគោត្របុព្វបុរសដូចប្តីក្នុងអនាគត ៗ តាមគម្ពីរ

គោតម (IV, 1) ប្រុសមិនត្រូវរៀបការជាមួយស្រីគោត្រជាមួយគ្នាទេ=សគោត្រ សមានប្រវរ ព្រោះចាត់ដូចជាសបិណ្ឌក្នុងគ្រួសារដែរ ។

x x x

ហិណ្ឌូធម៌ (ច្បាប់) .— ប្រពៃណីហិណ្ឌូត្រូវប្រតិបត្តិតាមច្បាប់ ដែលមានក្រោទុកក្នុងគម្ពីរ ច្បាប់នេះហៅថា "ធម៌" ជាច្បាប់ដែលអ្នកប្រាជ្ញបានចងក្រងទុក សម្រាប់ឲ្យប្រជាជនកាន់តាមនៅក្នុងគ្រួសារនីមួយៗ ដូចជាច្បាប់ក្នុងគម្ពីរព្រាហ្មណៈ ដែលកើតមានយូរមកហើយ ប្រហែលជារវាងសតវត្សទី ៨ មកដល់ទី ៣ មុនគ្រិស្តសករាជ ច្បាប់នេះមិនមែនជាវេទដែលហៅថា "ស្រុតិ នោះទេ គឺជាប្រពៃណីដែលហៅថា ស្ម្រិតិ" ។

ច្បាប់ប្រពៃណីនេះ ហៅថា ធម៌សាស្ត្រ ជាគម្ពីរមួយ

និយាយពីប្រពៃណីខ្លះពិធីដែលជាករណីយកិច្ចត្រូវប្រតិបត្តិ ៗ អត្ថបទនីមួយ ៗ នេះ ជាសូត្រ ហើយមានជាក់គាថានៅចនោះៗ ប្រាប់ឈ្មោះលទ្ធិ ឬ ប្រពៃណីគ្រួសារព្រមទាំងពិធីផង ៗ គម្ពីរដែលចាស់ជាងគេ គឺគម្ពីរធម៌សាស្ត្ររបស់អ្នកប្រាជ្ញគោតម អ្នកប្រាជ្ញពៅធាយនៈ និង វាសិដ្ឋ ដកស្រង់ចេញមកពីគម្ពីរសាមវេទ គឺគេប្រមូលយកមកចប្រុះគ្នាទុកជាច្បាប់ ៗ ធម៌សូត្ររបស់អ្នកប្រាជ្ញ វាសិដ្ឋ ជារបស់លទ្ធិហិណ្ឌូភាគខាងជើង យកតាមគម្ពីរធម៌សូត្ររបស់មនុ វំងងជាដើម កំណើតគម្ពីរ មានវធម៌សាស្ត្រក្នុងបុព្វកាល សូត្ររបស់អ្នកប្រាជ្ញអាបស្តម្ភៈ ចេញមកពីគម្ពីរយជុរវេទខ្មៅ ជាលទ្ធិហិណ្ឌូភាគខាងត្បូង ប្រហែលជាកើតមានឡើង ៤០០ ឆ្នាំ មុនគ្រិស្ត-សករាជ ជាកាលបរិច្ឆេទមុនសូត្រៈរបស់អ្នកប្រាជ្ញពៅធាយនៈបន្តិច ៗ គម្ពីរទាំងពីរនេះ ជាគម្ពីរចាស់ជាងគេបំផុត គេដកស្រង់ចេញពីសូត្រៈ របស់លោកហារិតៈក្នុងវេទជាមួយគ្នា

តែជាលទ្ធិ មៃត្រាយណីយៈ ។

មួយទៀត គម្ពីរជាន់ក្រោយ មិនមុនគ្រិស្តសករាជ ២០០ ឆ្នាំទេ ដូចគម្ពីរធម៌សាស្ត្រនៃលទ្ធិវៃស្ណវៈ ហៅថា វិស្ណុស្ម្រឹតិ ដកស្រង់ចេញពីសូត្រៈចាស់នៃលទ្ធិកាឋកៈ ក្នុងគម្ពីរយជុវេទទៅ ។ ឯស្ម្រឹតិដទៃទៀត ដូចមនុស្ម្រឹតិ មួយទៀតហៅថា មានវធម៌សាស្ត្រជាដើម គម្ពីរនេះ អ្នកអឺរ៉ុបយកមកប្រែហើយ ហៅថា (Loi de Manu) ។ គម្ពីរទាំងនេះ កើតក្នុងសម័យគម្ពីរមហាភារតៈ ព្រោះមានជាប់លទ្ធិសាសនាប្រជា- ជនទូទៅ ដែលគេយកមកពីគម្ពីរមហាភារតៈ មានទាំងស្នាដៃសម្រាប់ខាងការបង្រៀន ខាងកវីនិពន្ធ ខាងទស្សនវិជ្ជាផង ផ្ទុយគ្នានឹងគម្ពីរជាន់ចាស់ ដែលក្រៀមក្រោះមិនមានរសជាតិអ្វី ។ ឯស្ម្រឹតិរបស់លោកយជ្ញវល្ក្យ កើតក្នុងសម័យជាមួយគ្នាដែរ តែជារបស់គ្រឹហ្យសូត្រក្នុងគម្ពីរយជុវេទស ជារបស់លទ្ធិហិរណ្យ

ភាគខាងកើត មានពាក្យពេចន៍ច្បាស់លាស់ហ្មត់ចត់ ហើយ ប្រសើរជាងគម្ពីរមនុះទាំងទៀត ហើយមានចំណងជួបស្ម្រតិរបស់ លោកខាងទេៈ ៗ ឯស្ម្រតិរបស់លោកពហុស្សូត មើលឲ្យល្អិត ទៅ ឃើញថាកើតមុនស្ម្រតិខាងទេៈ ប៉ុន្តែបែបជាគល្លកជារបស់ មនុស្ម្រតិ ហើយកើតមុនស្ម្រតិរបស់លោកបេតាភិច ដែលជា អ្នកតាំងច្បាប់មុនដំបូង ជាបែបបុរាណ (Classique) ក្នុង គ្រិស្តសាវក្យរបី ៤ ៗ គម្ពីរផ្សេង ៗ ជាដើម សុទ្ធតែមាន និយាយពីប្រពៃណី ដែលគេប្រើគង់សម័យ គម្ពីរចប់តាស្រុតី បុរាណ និងតាំងពីចាស់ ៗ ពីបុរាណទៀតផង ហើយទុកជា បែបការសិក្សាខាងប្រពៃណីនិយម (Folklore) ពាសពេញ ទ្វីបអាស៊ី ។

និយាយដោយឡែក សង្គមឥណ្ឌា ជាសង្គមចាក់ទង

ដោយលទ្ធិសាសនា ។ ទស្សនវិជ្ជាទេពនិយម (Philosophie Panthéistique) នៃជនហិណ្ឌូ បដិសេធមិនឲ្យមានសេចក្តីយល់ឃើញជាឯកតាធិបតេយ្យទេ (Individualisme) តែបើនិយាយតាមការគាំទ្រចិត្តប្រតិបត្តិវិញ ជនហិណ្ឌូជាឯកតាធិបតេយ្យ ។ រចនាសម្ព័ន្ធ (Structure) នៃសង្គមហិណ្ឌូ មានការបែកវណ្ណៈជាបួន ហើយមានចិត្តប្តូន់លំអៀងទៅខាងការប្រកាន់វណ្ណៈនេះណាស់ ។ របៀបការបែកវណ្ណៈនេះជាការនាំឲ្យបែកសង្គម មិនមែនជាការនាំឲ្យមានសាមគ្គីជាឯកភាពទេ ។ វណ្ណៈមួយ ៗ មានអនុវណ្ណៈតទៅទៀត ហើយហាមមិនឲ្យស៊ីជាមួយគ្នា មិនឲ្យរៀបការជាមួយគ្នា មិនតែប៉ុណ្ណោះទេ ការទាក់ទងគ្នា ក៏ត្រូវមានការកំរិត សព្វបើស៊ីបាយជាមួយវណ្ណៈជាមួយគំដោយ ហើយមានពិធីសម្រាប់លាងបាបទៀត ។ កំរិតការទាក់ទងនៅលើសង្គមបែបនេះ នាំឲ្យជនហិណ្ឌូមានគំនិត ដើរចេញពីសង្គមទៅស្វះស្វែងរកឃើ

បានស្ងប់ស្ងាត់ ដែលនាំផងនេះគឺគតិលទ្ធិសាសនាក្នុងការសំរា សគ្គីយ តែសហគមមិនអាចនឹងបិតបោះបង់ចោលបានទេ. ប្រសិនបើមិនមានការជាប់គ្នាខាងសង្គមកិច្ច ។ ជនហិណ្ឌូទាំងអស់ត្រូវកាន់ច្បាប់នេះដោយដាច់ខាត មិនមានការវៀរលែងឡើយ ។

ជនហិណ្ឌូដែលជាវណ្ណៈ នៅជនបទក្តី នៅក្រុងក្តី តែងមានគណៈបញ្ចាយ័ត (Pancayat) មួយ សម្រាប់វណ្ណៈរបស់ខ្លួន ៗ បញ្ចាយ័តនេះ ជាស្ថាប័នហិណ្ឌូពីបុរាណជាក្រុមជនអ្នកកាន់អំណាចសម្រាប់សម្រេចសេចក្តី ពីការទាស់ទែងគ្នាតាមផ្លូវច្បាប់ ។ ពាក្យថា បញ្ចាយ័តបានសេចក្តីថា "សមាជន ៥ នាក់" តែចំនួននេះ មិនមែនជាការកំណត់ទេ ឯសមាជិកបញ្ចាយ័តនេះទៀតសោត ក៏មិនមានការៈធូន ឬ ថេរទេដែរ ក្នុងជនបទខ្លះ អ្នកកាន់អំណាចតែងតាំងឡើង ជនបទខ្លះទៀត អ្នកស្រុកជ្រើសតាំងឡើង ឯជនបទដទៃទៀត កាន់តៗ គ្នាពីដូនតាមកក៏មានដែរ គណៈជនបញ្ចាយ័តនេះ

មានទំនងដូចមេត្តាទៅតាមភូមិពីបុគ្គល មានសិទ្ធិត្រូវពិន័យ ទោស ឬដាក់ទោស ឬកំដេញពីវណ្ណៈខ្លួន ។ ការបណ្ដេញ ពីវណ្ណៈនេះ ជាការយោរយៅណាស់ ។ ឯសកម្មភាព ក្នុងការកំណត់វេក្កនៃអន្តរវណ្ណ របស់ខ្លួននេះ ជាការសំខាន់ខាង សង្គមនិងខាងសាសនា ជនបាណ្ណ ដែលត្រូវគេបណ្ដេញចេញ ពីវណ្ណៈហើយមិនត្រូវមានកូនស្រីប្រុសរៀបចំការ ។ មិនត្រូវ ទទួលធាក្ដៈខាបទាភមិតការ (ឬពាក់ទងនឹងក្រុមគ្រួសារ)។ នូវមិត្តវណ្ណៈខ្ពស់ ដែលត្រូវគេបណ្ដេញហើយ វណ្ណៈភាប ក៏មិនត្រូវព្រមទទួលទៀតជាមួយខ្លួនដែរ ព្រោះគេប្រកាន់ជឿ ថាជា "យូតា=ការចាក់ភាប" ចង្រៃធំណាស់ វណ្ណៈដទៃទាំង អស់ ត្រូវហាមដាច់ខាតមិនឲ្យទទួលគ្រួសារអ្នកដែលគេត្រូវ បណ្ដេញនេះទេ គ្រាន់តែការពាល់ត្រឹមដីករបស់ខ្លួនក៏មិន បានដែរ ។

ការបណ្ដេញពីវណ្ណៈនេះ មានការខ្លះក៏ត្រូវបណ្ដេញ ការ

ខ្លះទៀតក៏មិនត្រូវបណ្ដេញដែរ ការត្រូវបណ្ដេញនោះគឺសម្រាប់គេ ស៊ីសាច់គោ ឬស៊ីបាយជាមួយវណ្ណៈទាប ធ្វើដំណើរឆ្លងសមុទ្រ បើមិនដឹងហើយទៅស៊ីបាយរបស់ជនវណ្ណៈទាបដូចដាំឲ្យ ត្រូវបណ្ដេញអ្នកនោះ ។ សង្គមហិណ្ឌូ ជាសង្គមតាមលទ្ធិសាសនា មានគណៈបញ្ញវ័តជាអ្នកនាំមើលការខុសត្រូវគ្រប់វណ្ណៈខ្លួន ជាប្រពៃណីបរមបុរាណយូរយារណាស់ហើយ គេរក្សាទុករហូតមកដល់សព្វថ្ងៃនេះ, តែជនហិណ្ឌូសម័យថ្មីមិនកាន់តាមប៉ុន្មានទេ ។

វណ្ណៈ.- សង្គមហិណ្ឌូ មានការបែកមនុស្សជាតិជាជាន់ថ្នាក់ខ្ពស់ទាប ។ ការបែងចែកបែបនេះ គេឲ្យឈ្មោះជា វណ៌ (ប.វណ្ណ) ប្រែថា "ពណ៌" ហើយអ្នកអង្គគ-ប្រទេសហៅថា កស្តិ (Caste) ។ "កស្តិ" នេះ ជាពាក្យពរទុគេស៍ ប្រែថា "ជាតិ,កំណើត" មិនមានន័យសមរម្យទៅតាមវណ្ណៈហិណ្ឌូទេ ។ រឿងការបែងចែកវណ្ណៈនេះ កើត

មានះឡើងក្នុងសម័យនេះ ជារឿងសំខាន់ណាស់ ក្នុងសម័យនោះ ៗ ឯបុព្វហេតុដើម ដែលនាំបង្កបង្កើតឲ្យមានវណ្ណៈខ្ពស់ទាបដូច្នេះឡើង គឺកើតមកពីការរុករានពីខាងក្រៅ នៃពួកជនដែលមានអានុភាពច្រើនជាង ចូលមកក្នុងដែនដីណាហើយតាំងទីហានលំនៅរបស់ខ្លួន ៗ កាលជនពួកនេះ មកតាំងទីហានលំនៅមាំមួនហើយ គឺកើតជាប្រស្នាវណ្ណៈនេះឡើង ដើម្បីប្រកាន់កុំឲ្យលាយឡំជាតិខ្លួន ហើយលើកដំកើងឈ្មោះពួកខ្លួនថាអារ្យ័ន ប្រែថា "ប្រសើរ ឬមានះសក្ការ" ឯផ្ទុ-ក់សីអ្នកដើមកំណើតស្រុក ជាកុលសម្ពន្ធ ទ្រាវិឌ, មីលក្ខ "អ្នកព្រៃ ឬ អ្នកធំ", ទាស, ទស្យុ (ដែលគេទុកជាឈ្លើយ ឬជាអវៈសត្រូវ) ក៏មកមានន័យនេះទៅជា "ខ្ញុំកំដរ" ទៅវិញ ៗ បុព្វហេតុមួយទៀត អ្នកប្រាជ្ញខ្លះយល់ថារឿងពណ៌សម្បុរស្បែក ព្រោះពួកអារ្យ័នជាជាតិពណ៌ស្បែកស ឯពួកដើមស្រុក មានកុលសម្ពន្ធ ទ្រាវិឌជាដើមនោះ ជា

ជាតិស្បែកពណ៌ខ្មៅ ។ លុះពួកស្បែកពណ៌សចូលមកនៅបានធ្វើជាចៅហ្វាយនាយហើយ ក៏កើតមានការមើលងាយពួកដើមស្រុក ដែលមានស្បែកពណ៌ខ្មៅ ហើយដែលធ្លាក់ខ្លួនមកជាទាសៈរបស់ខ្លួនទៀត នេះហើយជាហេតុដើមដែលនាំឲ្យបែងចែកមនុស្សជាតិជាជាន់ថ្នាក់ ដោយប្រកាន់យករឿងពណ៌សម្បុរស្បែកនេះមកជាបទដ្ឋាន ។ តមកក្ដីកាលជាខាងក្រោយ រឿងការបែងចែកវណ្ណៈនេះ ក៏ក្លាយទៅជាច្បាប់ប្រពៃណីសង្គមឡើងហៅថា "វណ្ណធម៌" ។

នេះជាសម្ពន្ធនៃសង្គមវណ្ណ ដែលហៅថាក្រមធម៌ ប្រែថា "ច្បាប់របស់វណ្ណៈ ៤ និងការគ្រង គឺតំណែងក្នុងការគ្រងជាន់ ៤ នៃជីវិតព្រាហ្មណ៍" ។ កាលដើមឡើយ គង់សម័យវេទពួកអារ្យ័ន ចែកវណ្ណៈត្រឹមតែ ៣ គឺ ព្រាហ្មណៈ ក្សត្រិយៈ និង វៃស្យ ដូចនៅប្រទេសអ៊ីរ៉ង់ (Iran) ដែលមានតែ ៣ ដែរ គឺ អប្រេវ៉ន (Athrevans) ពួកអ្នកបួស, រថេស្ដារ

(Rathaesthes) ពួកអ្នកចម្បាំង និង វាស្រ្ដិយស-ឝូយទ្យ (Vastriyas Fshouyants ឬ Huitis) ជាប្រជាជនទូទៅ (La masse populaire) ។ ទីបំផុត រឿងនេះក៏កើតទៅជាវណ្ណៈ ៤ គឺ ព្រាហ្មណៈ ១ ក្សត្រិយៈ ១ វៃស្យៈ ១ ឝូទ្រៈ ១ ។ ការបែងចែកជាវណ្ណៈ ៤ យ៉ាងត្រឹមប៉ុណ្ណោះ នៅមិនទាន់គ្រប់គ្រាន់ទេ ត្រូវមានច្បាប់បញ្ញត្តិឲ្យមានគ្រឿងស្លៀកពាក់ មានពណ៌ផ្សេងៗ គ្នា ទៀត គឺ ព្រាហ្មណ៍ស្លៀកពាក់ ពណ៌ស ក្សត្រិយ៍ស្លៀកពាក់ពណ៌ក្រហម វៃស្យៈស្លៀកពាក់ពណ៌លឿង ឝូទ្រៈ ស្លៀកពាក់ពណ៌ខ្មៅ ពួកវណ្ណៈខ្ពស់និងពួកវណ្ណៈទាប សមាគមជាមួយគ្នាមិនបានទេ ដេកបន្ទប់ជាមួយគ្នា ឬបរិភោគអាហារជាមួយគ្នាក៏មិនបាន ហាមប្រាមមិនឲ្យដណ្ដឹងយកវណ្ណៈខុសគ្នាជាស្វាមីភរិយា ដោយដាច់ខាត បើណាតែកន្ទ ទៀតគឺ វណ្ណៈខ្ពស់ទៅយកវណ្ណៈទាបជាស្វាមីភរិយា ហើយមានកូនកើតមក កូននោះ ត្រូវមានគ្រោះកាចចៅនៃសេក្រក់

ណាស់ ជាមតិតព្រោះកើតមកត្រូវគេហៅថាកូន "ចណ្ឌាល" ថោកទាបបំផុតជាងសត្វតិរច្ឆានទៅទៀត ។

រឿងកំណើតវណ្ណៈនេះ ហាក់ប្រែប្រួលណាស់ ក-តិប្បាយមិនអស់ណើនទេ បើមានការផ្លាស់ប្តូរលក្ខណ៍ តាមរូប-វណ្ណៈនេះ ក៏ត្រូវមានន័យផ្សេងទៅទៀត តែបើពិត ក៏មិនមានផ្លាស់ប្តូរ ព្រោះនៅតែមានវណ្ណៈដ៏ដដែលនោះឯក បើទុកជាសាសនាព្រហ្មណ៍ ផ្លាស់ប្តូរទៅជាយ៉ាងណាក៏ដោយ វណ្ណៈក៏នៅតែជាវណ្ណៈដដែល ផ្លាស់ប្តូរទៅណាមិនបាន ។ ។ សម័យពុទ្ធកាលៈ យើងបានដឹងថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់បានព្យាយាមបំផុត ទ្រង់បានសំដែងពីវណ្ណៈនេះដោយល្អិត ដើម្បីបដិវត្តសង្គមហិណ្ឌូឲ្យបានប្រសើរ តែការនេះមិនបានសម្រេចផលល្អទេ ។ សេចក្តីនេះ មានមនុស្សខ្លះនិយាយថា ពុទ្ធសាសនាជាសាសនាចំលាយបន្ទូរវណ្ណៈ ថានេះបើសទៅសមដែរ តែដោយពិត ព្រះសម្ពុទ្ធទ្រង់គ្រាន់តែកែញែកឲ្យ

ឃើញទោសវណ្ណៈជាក់ស្តែងប៉ុណ្ណោះទេ ទ្រង់មិនមានព្រះកដ-ហឫទ័យប្រកបដោយអគតិឡើយ ។ បើគ្រាន់តែទ្រង់សំដែងប្រាប់ខុសត្រូវ ដោយព្រហ្មវិហារធម៌ គេឃើញយល់ថាទ្រង់បំផ្លាញរបស់គេពាលដែរឬអ្វី ?

ក) វណ្ណៈព្រាហ្មណ៍.– ព្រាហ្មណ៍ជាធំខាងផ្នែកសាស-នា ហើយមិនព្រមទុកដាក់វណ្ណៈខ្លួនជាទាបជាងក្សត្រិយ៍ទេ ទុកវណ្ណៈខ្លួនជាវណ្ណៈនៃសង្គមទីមួយ ព្រាហ្មណ៍ស្ត្រីក៏បាននាមថាជាព្រាហ្មណី កូនកើតមកក៏បាននាមថា ជាព្រាហ្មណ៍ទៀត គ្រាន់តែមិនទាន់ពេញលក្ខណៈសម្បូណ៌ប៉ុណ្ណោះ លុះគ្រាតែមានកិច្ចធ្វើពិធីបន្ទក់ប្រសិទ្ធិឲ្យទៅជាព្រាហ្មណ៍ទៀត ទើបបានជាព្រាហ្មណ៍ពេញលក្ខណៈ ហេតុនេះហើយបានជាព្រាហ្មណ៍មានឈ្មោះមួយទៀតថា ទ្វិជៈ ប្រែថា "មានកំណើតកើតពីរដង" ដូចជាសត្វមានស៊ុតកើតពីរដង គឺកើតជាស៊ុតមុន កើតចេញពីស៊ុតមកម្ដងទៀត ។

មួយទៀត រឿងព្រេងដំណាលទុកថា ព្រាហ្មណ៍នេះ កើតមានឡើងដោយពួកតាបសបុរស ជ.មុនិ មុនប្រវត្តិសាស្ត្រ ដែលបង្កើតពាក្យថា "ព្រហ្មន៍" នេះឡើង ហើយយកឈ្មោះខ្លួនថា "ព្រាហ្មណ៍" ជាបន្ទាន់ ពាក្យថា ព្រហ្មន៍ នេះ បើតាមន័យខាងនិរុត្តិសាស្ត្រ គឺជា ទេវតាទៅហៅមនុស្សលោកយើងនេះ ហើយជាតំណែងសង្គមមនុស្សលោកផង ។ តាមគម្ពីរមនុ មានសេចក្តីថា ព្រាហ្មណ៍នេះ កើតចេញមកពីមាត់ព្រះព្រហ្ម (ឬថាជាមាត់ព្រះព្រហ្ម) ជាអ្នកធ្វើពិធីយញ្ញៈ ។ កំណើតព្រាហ្មណ៍ ឬ ព្រហ្មន៍ គឺជាអវតារនៃធម៌ៈ ជាអាទិទេពក្នុងសាសនាព្រាហ្មណ៍ ។ មាត់ព្រាហ្មណ៍ជាមាត់អាទិទេព រីមួយដែលគេយកទៅដាក់ក្នុងមាត់ព្រាហ្មណ៍ អាចនាំឲ្យកើតសេចក្តីចំរើនដល់ពិភពលោកបាន សមដូចពាក្យថា៖

ពិភពលោកទាំងមូលនៅក្រោមអំណាចអាទិទេព

— អាទិទេពនៅក្រោមអំណាចមន្ត្រ៖

– បទ្រ: នៅក្រោមអំណាចព្រាហ្ម... ព្រហ្មន

– ដូច្នេះ ព្រាហ្មណ៍ជាអាទិទេពរបស់យើង ។

កាយព្រាហ្មណ៍ជាវត្ថុសក្តិសិទ្ធិ ការសម្លាប់ព្រាហ្មណ៍ មានទោសធ្ងន់ណាស់ ទុកដូចសម្លាប់ទេពតា ការបៀតបៀន កាយព្រាហ្មណ៍ មានទោសធ្ងន់បន្ទាប់មកទៀត ។ ក្សត្រិយ៍ មិនមានច្បាប់នឹងប្រទុស្តដល់រូបកាយព្រាហ្មណ៍ទេ បើក្សត្រ: សម្លាប់ព្រាហ្មណ៍ អ្នកប្រព្រឹត្តបាវឃាតកម្មនេះ ត្រូវមានទោស ដល់ស្លាប់ ។ ជីវិតព្រាហ្មណ៍ចែកទៅជាកស្រមប្អំណែង (Stages) មាន ៤ ប្រការគឺ ព្រហ្មចយ៌ ១ គ្រហស្ថ ១ វន-ប្រស្ថ ១ សន្យាសិន ១ ។

១– កាលនៅវ័យក្មេង កុមារព្រាហ្មណ៍ជាអន្តេវាសិក ត្រូវ សិក្សាត្រៃវេទ មានឈ្មោះថា ព្រហ្មចារិន កុមារនេះ ត្រូវ ប្រព្រឹត្តព្រហ្មចយ៌ ហើយមានភារៈរកឧស សម្រាប់ដុតបំពក់ បង្ក្រានអគ្គិ ដើរសូមទានអាហារពីពួកញាតិសន្ដាន ដេកលើ

ក.សងៈភាព ប្រតិបត្តិតាមទ្រង់ក្នុងអាស្រមបក ត្រូវមានគ្រូ
ជឿនរៀនផលស្គាល់ផ្លូវ និងមានគុរុគ្រូមាតីជាអ្នកប្រាជ្ញាស្ដាប់គ្រូ
រហូតដកបដល់ត្រឡប់មកកាន់ផ្ទះបិតាខ្លួនវិញ ការប្រព្រឹត្តិនេះ
ហៅថា ព្រហ្មចរិយ៍ អ្នកប្រព្រឹត្ត ហៅថា ព្រហ្មចារិន ។ល។

២– កាលសិក្សាត្រូវចប់ហើយ ត្រឡប់មកផ្ទះវិញ
កុមារត្រូវរៀបចំធ្វើអាពាហមង្គលតីមានភរិយា ដើម្បីឲ្យទៅជា
ម្ចាស់ផ្ទះ ហៅថា គ្រូហបតិ ត្រូវប្រព្រឹត្តធម៌ ៣ ប្រការគឺ
អត្ថ-កាម ធម៌(១) ហើយមានភារៈត្រូវបំពេញកិច្ចការគោរពតីធ្វើ
គ្រឿងសែនចំពោះទៅបុព្វបុរស ដែលចែកឋានទៅហើយ
ការប្រព្រឹត្តិនេះ ហៅថា គ្រូហស្ថ ។ល។

---

១– ហៅថា ត្រិវត៌ ឬ ត្រិគណៈ សភាព ៣ ប្រការនេះគឺ អត្ថៈ ធ្វើឲ្យចំរើន = វឌ្ឍនធម៌ (Progrès), កាមៈ បរិភោគកាម = សភាពតាំងនៅ (Etat stationnaire), ធម៌ៈ វកធម៌ = ការលត់ទៅ (Déclin)

៣– លុះបានបំពេញកិច្ចជាគ្រួហស្ថបរិបូណ៌ហើយ ព្រាហ្ម-ណ៍នេះ ត្រូវប្រគល់ គ្រួហស្ថភាពជាគហបតិ (Succession) ទៅឲ្យកូនហើយចេញទៅនៅព្រៃ ស្នឹងស្នាធ៌អប់រំបន្ទុំអាត្មាឲ្យបានប្រពៃឡើង ហៅថា វនប្រស្ថ ។ ល ។

៤– លុះបានស្នឹងស្នាធ៌អប់រំបន្ទុំអាត្មាប្រពៃហើយ ព្រាហ្មណ៍នេះ បានអាស្រម ឬគំណែនទី ៤ ហៅថា សន្យាសន អ្នកប្រព្រឹត្ត ហៅថា សន្យាសិន ប្រែថា អ្នកប្រព្រឹត្តបង់លះលោកនេះទៅធ្វើជាតាបសឬជាភិក្ខុ ។

១) វណ្ណៈក្សត្រិយ៍.– ក្សត្រិយ៍ (ប.ខត្តិយ) ប្រែថា អ្នកចម្បាំង មាននាទីជាអ្នកពង្រីកខេត្តដែន ព្រមទាំងរក្សាខេត្តដែនទុកឲ្យគង់ដោយប្រពៃ ប្រកាន់ជឿថាខ្លួនជាខ្សែស្រឡាយតមកពីព្រះអាទិត្យដែលហៅថា សរិយ្យ ។ ឯព្រះនាមព្រះសម្ពុទ្ធថា គោតម នោះ ក៏បានសេចក្តីថា "ព្រះអាទិត្យ" ដែរ ។

មួយទៀត ក្សត្រិយ៍នេះ ក្នុងគម្ពីរព្រាហ្មណ៍ កើតចេញមកពីដៃព្រះព្រហ្ម (ឬជាដៃព្រះព្រហ្ម) មានភារៈជាអ្នកគ្រងសង្គម មិនឲ្យមានការបៀតបៀនមកពីខាងក្រៅ ។ តាមច្បាប់ ក្សត្រិយ៍ ត្រូវធ្វើជាស្តេចនិងទាហាន (អ្នកចម្បាំង) ឬជាខ្លួនសម្រាប់ការពាររក្សាព្រាហ្មណ៍និងគោ ហើយត្រូវយកព្រាហ្មណ៍ដែលមានក្តីឈ្លាស មានការចេះដឹងក្នុងវេទនិងធម៌-សាស្ត្រទាញមកធ្វើជាបុរោហិត ។ល។

គ) វណ្ណៈវៃស្យ.- វៃស្យ (ប.វេស្ស) បានដល់អ្នកជំនួញ តែមិនមែនស៊ីសេចក្តីត្រឹមតែអ្នកជំនួញទេ អ្នកជំនួញសម័យនេះ មិនមែនដូចអ្នកជំនួញសម័យយើងនេះទេ ព្រោះអ្នកធ្វើស្រែចំការ ក៏ចាត់ទុកនៅក្នុងពួកវៃស្យ អ្នករកស៊ីចិញ្ចឹមជីវិតដទៃទៀត ក៏គេទុកថាជាវៃស្យ លើកលែងតែទាសកម្មករប៉ុណ្ណោះចេញ ។

មួយទៀតវៃស្យ តាមគម្ពីរព្រាហ្មណ៍គេថា កើតចេញមក ពីភ្លៅព្រះព្រហ្ម (ឬជាភ្លៅព្រះព្រហ្ម) មានការៈជាអ្នកធ្វើផលិតផលឲ្យកើតបរិបូណ៌ឡើងដល់ប្រទេសជាតិ ហើយត្រូវដាក់ពន្ធដល់ព្រាហ្មណ៍និងក្សត្រិយ៍ ព្រមទាំងកសាងសេនាសនៈ មានវិហារជាដើម ឬជាដល់ព្រាហ្មណ៍ទៀតផង ៗ វៃស្យនេះជាព្រាហ្មណ៍ដែរ ព្រោះជាជាតិតែមួយដូចគ្នា តែមានឋានៈទាបបន្តិច ៗ

ឃ) វណ្ណៈសូទ្រៈ.– សូទ្រៈ (ប.សុទ្ទ) បានដល់ពួកអ្នកគ្រួ ឬ អ្នកស៊ីឈ្នួល ដូចពួកកម្មករយើងក្នុងបច្ចុប្បន្នកាលនេះ ៗ វណ្ណៈនេះថោកទាបជាងគេបំផុត ៗ

មួយទៀត សូទ្រៈ ក្នុងគម្ពីរព្រាហ្មណ៍គេថា កើតចេញអំពីបាទជើងព្រះព្រហ្ម (ឬជាជើងព្រះព្រហ្ម) បានជាគេទុកដាក់ថាថោកទាបជាងគេ ៗ មានវណ្ណៈថោកទាបជាងសូទ្រៈនៅទៀតហៅថា អនុវណ្ណៈ ឬ ហីនជាតិ ដូចពួកចណ្ឌាល

ជាដើម រួមពួកវណ្ណៈថោកទាបទាំងអស់នេះ ហៅថាបញ្ចមៈ អ្នកអស្ពឹត ហៅថា F.Hors castes Intouchables, A.outcastes ហើយមានឈ្មោះសម្រាប់ហៅផ្សេង ៗ គ្នាតាមផងបង ៗ ក្នុងគម្ពីរមនុ មានសេចក្ដីថា បើកូនកើតពីនាងព្រាហ្មណីដែលមានប្ដីជាវណ្ណៈសូទ្រៈ កូននោះត្រូវជាកំពុះជាចណ្ឌាល ទាបថោកបំផុតជាងសត្វតិរច្ឆានទៅទៀត ។ វណ្ណៈ ទាំង ៤ នេះ សុទ្ធតែមានគណៈបញ្ចាយ័ត ជាអ្នកគ្រប់គ្រងក្នុងក្រុមនីមួយរៀងតទៅ រហូតមកដល់សព្វថ្ងៃនេះ ។

តាមទស្សនៈខ្ញុំទៅ ការបែងចែកវណ្ណៈនេះ មិនមែនជាប្រពៃណីប្រសើរទេ ព្រោះមិនមែនជារបបសង្គមប្រសើរ ជាហេតុនាំឱ្យបែកសាមគ្គីរវាងសង្គម មិនមែនជាហេតុនាំឱ្យកើតសាមគ្គីនិងសេចក្ដីសុខចំរើនទេ តែសព្វថ្ងៃនេះការប្រកាន់វណ្ណៈទន់ទន្លាយបន្តិចទៅខ្លះដែរ មិនមែនតឹងរឹងដូចសម័យមនុដែលបង្កើតច្បាប់សម្រាប់ជនសម័យនោះទេ អាស្រ័យដោយ

ហេតុផ្សេង ៗ ដូចជាជនហិណ្ឌូទៅលាយឡំជាមួយនឹងជនជាតិ
ដទៃឬលទ្ធិដទៃ ៗ ដូចគ្រិស្តជាដើម ឬដោយជនហិណ្ឌូជាន់
ថ្មីដែលបានទទួលយកវប្បធម៌ពីរស្ដ្តប្រទេស ក៏កើតមាន
គំនិតថ្មី ៗ ជាច្រើន ៗ គេឃើញថាវណ្ណៈទាំង ៤ ក្នុងកាល
ឥឡូវនេះ ប្រៀបដូចជាកាដេដាក់ទឹកនោះ ដែលកំពុងរលាយ
ហរិជនអាចចូលទៅក្នុងវិហារហិណ្ឌូ ហើយដើរមើលតាមចិត្ត
ពួកជនហិណ្ឌូខ្ពុះខ្ពស់វណ្ណៈ ទៅតាមសណ្ឋាគារ មានការ
លាយឡំជាមួយជនជាតិផ្សេង ៗ កាន់សាសនាផ្សេង ៗ ដូច
ជាឥស្លាមឬគ្រិស្តជាដើម តែនៅតាមជនបទក្នុងប្រទេសឥណ្ឌា
គេឃើញមានការប្រកាន់វណ្ណៈនៅឡើយច្រើនដែរ ព្រោះការ
សិក្សាសម័យថ្មី មិនទាន់ជ្រួតជ្រាបបរិបូណ៌ ៗ

x

x x

# អក្សរសាស្ត្រវេទ

| វេទ | សាខា | សំហិតា | ព្រាហ្មណៈ | អារណ្យកៈ | ឧបនិស័ទ | កល្បសូត្រ |
|---|---|---|---|---|---|---|
| ឫគ្វេទ | អៃតរេយិន | | អៃតរេយ | អៃតរេយ | អៃតរេយ | អាស្វលាយនៈ |
| | កៅសីតកិន | ឫគ្វំហិតា | កៅសីតកី(សាំខ្យាយន) | កៅសីតកី | កៅសីតកី | សាំខ្យាយនៈ |
| យជុវ៌េទ ខ្មៅ | កាឋកៈ | កាឋកៈ | កាឋកៈ(មួយចំណែកនៅក្នុងតៃត្តិ.អារ.) | | តៃត្តិរីយ | បៅធាយនៈ |
| | តៃត្តិរីយ | តៃត្តិរីយ | តៃត្តិរីយ | តៃត្តិរីយ | មហានារាយណៈ | Āpastamba- ហិរណ្យកេសិ |
| | មៃត្រាយណីយ | មៃត្រាយណី | | | ស្វេតាស្វតរ | ភារទ្វាជ |
| | កបិស្ថលកឋ | កបិស្ថល | | | | |
| យជុវ៌េទ ស | មាធ្យន្ទិន | មាធ្យ.វាជសនេយី | ឝតបថ | មាធ្យ.វាជសនេយី | ព្ឫហទារណ្យក | កាត្យាយនៈ |
| | កាណ្វៈ | កាណ្វីយ.វាជសនេយី | | កាណ្វីយ | ឦឝា | លាត្យាយនៈ |
| សាមវេទ | កៅថុម | កៅថុមរាណាយនីយ | តាណ្ឌ្យ មហា | + | ឆាន្ទោគ្យ | គោភិល<br>ខាទិរ<br>សាមវិធានៈព្រាហ្មណ |
| | តលវការ (ជៃមិនីយ) | ជៃមិនីយ | ជៃមិនីយ.តលវការ | + | កេន | ជៃមិនីយ |
| អថវ៌វេទ | ឝៅនក | + | + | + | មុណ្ឌក<br>ប្រឝ្ន<br>មាណ្ឌូក្យ | កៅឝិក<br>វៃតានៈ |